សារព័ត៌មាន ខ្មែរផុស ស.រ.អា
KhmerPost USA
Vol. 15. Issue 363, June 20, 2024 | Direct: 978-656-8141
Lowell - Lynn - Revere - MA * Providence - Cranston - RI

Free Copies
Email:Khmerpostusa@gmail.com
www.khmerpostusa.com

# ខ្មែរក្រោមនៅតែមិនមានសិទ្ធិសេរីភាព ក្រោមការត្រួតត្រារបស់វៀតណាម

ដោយ លី ហេង

សហព័ន្ធខ្មែរកម្ពុជាក្រោមទាមទារ ឲ្យរដ្ឋាភិបាលវៀតណាម គោរពសិទ្ធិ

តទៅទំព័រទី០៤



Khmer Krom people gathered in Phnom Penh on June 9, 2024 to commemorate the 75th Anniversary Lost of Kampuchea Krom territory to Vietnam.

# Khmer Krom People Do Not Have Freedom Under Vietnamese Rule

By Ly Heng, Khmer Post USA

The Khmer Kampuchea Krom Federation demands that the Vietnamese government respect the rights of the Khmer Krom people from the abuses of

Please see /04



ថ្នាក់ដឹកនាំសមាគមខ្មែរកម្ពុជាក្រោមប្រារព្ធពិធីខួប៧៥ឆ្នាំនៃការបាត់បង់ការគ្រប់គ្រង ទឹកដីខ្មែរកម្ពុជាក្រោមទៅវៀតណាម និងមានការចូលរួមពីលោក សឺន សុប៊ែរ ជួបជុំគ្នានៅភ្នំពេញ

## ចាប់ផ្តើមការកាត់ក្តីសកម្មជនអង្គការមាតាធម្មជាតកម្ពុជា ពីបទសមគំនិត

**Trial begins for Mother Nature Cambodia activists on conspiracy charge**

Please see /03

ដោយ៖ Gerald Flynn

•សកម្មជនបរិស្ថានដប់នាក់ប្រឈម

សូមអាននៅទំព័រទី០៣



## បោះឆ្នោតក្រុមប្រឹក្សាស្រុកខណ្ឌ ខេត្តនិងក្រុងនៅកម្ពុជា

*ពីអឺរ៉ុប ទី១ ខែមិថុនា ២០២៤*

ការបោះឆ្នោតសម្រាប់ជ្រើស

តទៅទំព័រទី១៣




ផែនទី រាជធានី ខេត្ត, នឹងក្រុង នៃកម្ពុជា

## ព្រឹទ្ធសមាជិកសភា ប្រោន (Brown) ព្រមានរដ្ឋបាលថា ការផ្តល់លក្ខខណ្ឌសេដ្ឋកិច្ចទីផ្សារវៀតណាមនឹងគំរាមកំហែង ដល់កម្មករ និងក្រុមហ៊ុនផលិតរដ្ឋ OHIO ចំណេញដល់ប្រទេសចិន

សូមអាននៅទំព័រទី០៨



## លោក ពូទីន មកដល់ វៀតណាម ដើម្បីចាប់ផ្តើមដំណើរទស្សនកិច្ចដ៏សំខាន់

សូមអាននៅទំព័រទី២៣





# ស.រ.អា: ទោសព្រហ្មទណ្ឌប្រវត្តិសាស្ត្ររបស់អតីតប្រធានាធិបតីត្រាំ

អឺរ៉ុប ទី០១មិថុនា២០២៤

បន្ទាប់ពី ៦សប្តាហ៍ នៃសវនាការដ៏ក្តៅគគុក នៅវិមានអាកាស«ម៉ាន់ហាត់តាន់» តុលាការអាមេរិកាំងនៅញូយ៉កបានប្រកាសសាលក្រមសម្រេច យ៉ាងកក្រើកផែនដី កាលពីថ្ងៃទី៣០ឧសភា២០២៤ ដោយអង្គ«យូរី»១២នាក់បានវិនិច្ឆ័យអស់រយៈពេល២ថ្ងៃហើយប្រកាសជាឯកច្ឆន្ទថាលោក«ឌណាល ត្រាំ មានកំហុស» ដោយបានក្លែងបន្លំប្រាក់សម្រាប់ឃោសនាបោះឆ្នោត យកទៅចាយវាយផ្ទាល់ខ្លួន ដើម្បីបានលុយនោះទៅបំបិតមាត់ លាក់បំបាំងរឿងសាហាយស្មន់ ជាមួយនារីតួរកុនអាក្រាតម្នាក់ នៅពេលឃោសនាបោះឆ្នោតប្រធានាធិបតី តទល់ជាមួយបេក្ខនារី ហ៊ីឡារី គ្លីងតុន កាលពីឆ្នាំ២០១៦ ។ លោកឌណាល ត្រាំ ត្រូវការតែសម្លេងរបស់អង្គ«យូរី»តែម្នាក់គត់ ឲ្យមានមតិជំទាស់តែរកមិនបាន... នេះគឺជាលើកដំបូងបង្អស់ហើយ នៃប្រវត្តិសាស្ត្រពីរជាន់ដ៏អស្ចារ្យ របស់ប្រធានាធិបតីអាមេរិកាំង ដែលមានប្រធានាធិបតីខ្លួន «ឡើងតុលាការព្រហ្មទណ្ឌ»ផង នឹងទទួល«ការមានទោសព្រហ្មទណ្ឌ»ថែមទៀត ពីតុលាការនៃទីក្រុងញូយ៉ក ជាទីដែលលោក ឌណាល ត្រាំ រស់នៅ។

កាលពីឆ្នាំ២០០៦នោះ ត្រាំ មានទំនាក់ទំនងផ្លូវភេទលួចលាក់ ជាមួយស្ត្រីតួរឯកកុនស្រាតម្នាក់ឈ្មោះដាញែល ស្ទាំមី ពេលដែលលោកត្រាំមានភរិយារួចទៅហើយ។ ដើម្បីកុំឲ្យរឿងអាស្រូវនេះបែកធ្លាយ ត្រាំ ក៏ទិញទឹកចិត្តនាង ស្ទាំមី ក្នុងតម្លៃ១៣ម៉ឺនដុល្លា លាក់បំបាំងកុំឲ្យធ្លាយ នៅពេលកំពុងឃោសនាយកឈ្នះឆ្នោត លើបេក្ខនារីប្រធានាធិបតីជាគូរប្រគួត ហ៊ីឡារី គ្លីងតុន ។ ពេលនោះបានជោគជ័យមែន ដោយមានបុគ្គលិកជំនិតម្នាក់ឈ្មោះ ម៉ាយកិល កូអិន ជាអ្នកជួយក្លែងបន្លំលើបញ្ជីគណនេយ្យឃោសនា ចំនួន៣៤ចំណុច ដាក់ថាជាបញ្ជីចំណាយឃោសនា(ម៉ាយកិលកំពុងជាប់គុកទៅហើយ) ចុះហត្ថលេខាលើ«សែក»ចំណាយដោយលោកត្រាំ ក្នុងការឃោសនាជាបេក្ខជនប្រធានាធិបតិ នៃគណបក្សសាធារណរដ្ឋ នៅពេលនោះ។

រីឯការប្រកាសកំណត់នៃទោស ដោយចៅក្រមរដ្ឋញូយ៉ក ជូអាន មើកិន ថានឹងមានទោសប៉ុណ្ណានោះ នឹងត្រូវធ្វើឡើងនៅថ្ងៃទី១១ខែកក្កដាខាងមុខ ដែលថា«តើលោក ឌណាល ត្រាំ ត្រូវអនុវត្តន៍ទោសរបៀបយ៉ាងណា?» ក្នុងករណីដូចនេះ លោកត្រាំអាចនឹងត្រូវដាក់ទោសជា ការផាកពិន័យ ឬក៏ធ្វើការបំរើប្រយោជន៍សាធារណៈ ឬក៏ អាចត្រូវជាប់គុក រហូតដល់៤ឆ្នាំផងក៏ថាបាន, ដូច្នេះនៅមុនពេលកំណត់នោះ មេធាវីលោក ត្រាំ អាចតវ៉ាបន្ថែមបាន, ហើយម្យ៉ាងទៀតក៏អាចប្តឹងទៅសាលាឧទ្ធណ៍ ឲ្យកាត់សេចក្តីសាជាថ្មីបាន បើមិនសុខចិត្តលើសេចក្តីសម្រេច លើទោសនៅបន្ទាប់ពីថ្ងៃ១១កក្កដា ទេនោះ។ នៅពេលចប់សវនាការ ចៅក្រមបានអនុញ្ញាត្តិឲ្យលោកត្រាំចេញទៅបាន ដោយសេរី មិនមានដាក់កំរឹតប្រាក់ធានាសម្រាប់នៅក្រៅឃុំអ្វីឡើយ។

តើការប្រកាសថាលោក«ត្រាំ មានទោសព្រហ្មទណ្ឌ»នោះ មានផលវិបាកយ៉ាងណាចំពោះការបោះឆ្នោតប្រធានាធិបតី?



ឌណាល ត្រម អតីតប្រធានាធិបតីអាមេរិក



ចូ បៃឌិន ប្រធានាធិបតីអាមេរិក




នៅពេលចេញពីសវនាការតុលាការក្រុងញូយ៉កម្តងៗ ឌណាល ត្រាំ តែងតែធ្វើសេចក្តីប្រកាសចំពោះអ្នកកាសែតថា «លោកមិនដែលធ្វើអ្វីខុសនឹងច្បាប់ឡើយ អ្វីៗគឺជាអំពើអយុត្តិធម្មរបស់រដ្ឋបាលលោក ជោ បាដិន នឹងរបស់គណបក្សប្រជាធិបតេយ្យរបស់គាត់ទាំងអស់ទៅវិញទេ»។ចំពោះបណ្តឹងមួយនេះបើមានទោស ហើយឲ្យអនុវត្តន៍នៅក្រៅការឃុំឃាំង លោកត្រាំនៅតែអាចធ្វើការឃោសនាបន្តរហូតដល់ពេលបោះឆ្នោត នាថ្ងៃទី៥វិច្ឆិកាបាន ហើយបើមានករណីទៅឧទ្ធណ៍ក្តី ក៏លោកត្រាំក៏អាចត្រូវត្រឡប់មកឡើងតុលាការនៅក្រោយពេលបោះឆ្នោតដែរ, ហើយដែលពិសេសនោះ បើលោកត្រាំនឹងជាប់ឆ្នោតជាប្រធានាធិបតីទៅវិញនោះលោកនឹងធ្វើការលើកលែងទោសខ្លួនឯង ដោយប្រធានាធិបតីថ្មីក៏បានដែរ។ នេះពុំមែនជាករណីព្រហ្មទណ្ឌតែមួយនោះទេ នៅមានករណីបណ្តឹងព្រហ្មទណ្ឌ៣ទៀត ដែលមិនទាន់ចូលសវនាការនៅឡើយដូចជាករណីវាយលុកដោយហឹង្សាចូល«វិមានកាពីតូល»បណ្តាលឲ្យស្លាប់កងកាពារច្រើនរូប ឬការប៉ុនប៉ងឃុបឃិតប្តូរលទ្ធផលហិបឆ្នោតជាដើម...។

ចប់សវនាការទី១ភ្លាម លោកត្រាំប្តេមឃោសនា យ៉ាងគគ្រឹកគគ្រេងភ្លាមថា«ខ្ញុំជាអ្នកទោសនយោបាយ!»ដើម្បីបំពេញបំណងនៃក្រុមគាំទ្រដាច់ណាច់របស់ខ្លួន ដែលរង់ចាំការចោទប្រកាន់ក្រុមបដិបក្សលោក ជោ បាយដិន ថាជាក្រុមជនផ្តាចការនិយម ពុករលួយ ធ្វើឲ្យប្រទេសចុះអូនថយធ្វើឲ្យពិភពលោកមានសង្គ្រាម... ។ ការចោទប្រកាន់នោះ មិនបានប៉ះពាល់ដល់ដំណើរការឃោសនារបស់ជោ បាយដិននោះទេតែផ្ទុយទៅវិញ ឌណាល ត្រាំ បានជួបប្រទះនូវការស្រកចុះនៃឱកាសសម្រាប់ឃោសនាខ្លួនឯងយ៉ាងធ្ងន់ធ្ងរទៅវិញ ដែលត្រូវរើបំរះឲ្យបានឆាប់ ។

ចំពោះប្រជាប្រិយភាពរបស់ឌណាល ត្រាំវិញ ទំនងជាពុំមានការរង្គោះរង្គើ ដូចការរង់ចាំទេ ពីព្រោះទិន្នន័យនៃកាស្ទង់មតិ បានឲ្យឃើញថា នៅមានការកំពស់ប្រកៀកប្រកិតគ្នានឹងលោក បាយដិន ដដែលអាចនឹងផ្លាស់ប្តូរទៅតាមស្ថានភាពឃោសនារបស់បេក្ខជននិមួយៗនៅឡើយ រហូតដល់ថ្ងៃបោះឆ្នោត ។ ការប្រការថា ត្រាំ មានទោស ជាផលចំណេញដល់ការឃោសនារបស់ ជោ បាយដិន ទៅលើក្រុមអ្នកដែលមិនទាន់សម្រេចចិត្ត ថាខ្លួនត្រូវគាំទ្រនរណា នៅឡើយ ក៏ប៉ុន្តែ នៅថ្ងៃប្រកាសទោសរបស់ ឌណាល ត្រាំ នៅថ្ងៃទី១១កក្កដានោះ ក៏ជាថ្ងៃដែលមានការប្រជុំពិភពលោកនៃអង្គការ«អូតង់»នៅទីក្រុងវ៉ាស៊ីនតុនដែរ, គេសង្ស័យថា បាយដិន អាចនឹងប្រើឱកាសដ៏ល្អនោះសម្រាប់វាយពន្លិច ត្រាំ ដោយនយោបាយការបរទេសក្នុងពិភពលោក ដែលអាចមានជាផលប៉ះពាល់ដល់ មហាសន្និបាទសម្រាប់តែងតាំងបេក្ខជនប្រធានាធិបតីរបស់គណបក្សសាធារណរដ្ឋ ដែលធ្វើនៅ៣ថ្ងៃបន្ទាប់នោះ ជាមិនខានឡើយ៕



# ចាប់ផ្តើមការកាត់ក្តីសកម្មជនអង្គការមាតាធម្មជាតកម្ពុជា ពីបទសមគំនិត

ដោយ៖ Gerald Flynn

ថ្ងៃទី ២៩ ខែឧសភា ឆ្នាំ ២០២៤

•សកម្មជនបរិស្ថានដប់នាក់ប្រឈមនឹងការជាប់ពន្ធនាគាររហូតដល់ មួយទស្សវត្សរ៍ ខណៈការកាត់ក្តីពួកគេកំពុងដំណើរការនៅកម្ពុជា ក្រោមការចោទប្រកាន់ពីបទឃុបឃិតគ្នាប្រឆាំងនឹងរដ្ឋាភិបាល។

•សមាជិកនៃអង្គការមាតាធម្មជាតិកម្ពុជាបានស្វះស្វែងរកជាយូរមកហើយ ដើម្បីបង្ហាញពីផលប៉ះពាល់ដល់បរិស្ថាន ដែលកំពុងកើតមាននៅទូទាំងប្រទេស រួមទាំងអ្នកជំនួញដ៏មានឥទ្ធិពល និងឥស្សរជននយោបាយ។

• ពួកគេប្រាំមួយនាក់បាននៅក្រៅឃុំរួចហើយ ហើយបានបរិហារនូវអ្វីដែលពួកគេនិយាយថា ខ្វះយុត្តិធម៌ពីរដ្ឋ។

ភ្នំពេញ៖ សវនាការលើសំណុំរឿងអង្គការមាតាធម្មជាតិកម្ពុជា ជាក្រុមសកម្មជនបរិស្ថានចុងក្រោយបង្អស់របស់ប្រទេសនេះ បានបើកសវនាការនៅសាលាដំបូងរាជធានីភ្នំពេញ នៅព្រឹកថ្ងៃទី២៩ ខែឧសភា។

សកម្មជនបរិស្ថានចំនួន ១០ នាក់ កំពុងត្រូវបានកាត់ទោសពីបទឃុបឃិតគ្នាប្រឆាំងនឹង រដ្ឋាភិបាលដែលជាបទចោទប្រកាន់ដែលអនុវត្តទោសដាក់ពន្ធនាគារពី ៥ ឆ្នាំទៅ ១០ ឆ្នាំ។

ក្នុងចំណោម ១០ នាក់នោះ មានតែ ៥ នាក់ប៉ុណ្ណោះដែលបានចូលរួមក្នុងពិធីបញ្ចុះសពដោយស្លៀកសម្លៀកបំពាក់ប្រពៃណីខ្មែរគឺ យឹម លាងហ៊ី លី ច័ន្ទតារាវុធ ថន រដ្ឋា ភួន កែវរស្មី និងឡុងគន្ធា។

លាងហ៊ីស្ថិតក្នុងចំណោមសកម្មជនអង្គការមាតាធម្មជាតិកម្ពុជាបីនាក់ដែលត្រូវបានកាត់ទោសពីបទរៀបចំផែនការប្រឆាំងរដ្ឋាភិបាល និងការប្រមាថព្រះមហាក្សត្រ។

(ពីឆ្វេងទៅស្តាំ) លី ច័ន្ទតារាវុធ ឡុងគន្ធា ភួន កែវរស្មី ថន រដ្ឋា និង យឹម លាងហ៊ី នៃអង្គការមាតាធម្មជាតិកម្ពុជា ថ្លែងលាអ្នកគាំទ្រមុនចូលតុលាការនៅថ្ងៃទី ២៩ ឧសភា ឆ្នាំ ២០២៤។ រូបភាពដោយ Gerald Flynn / Mongabay.

ការចោទប្រកាន់ទីពីរអាចបន្ថែមពីមួយឆ្នាំទៅប្រាំឆ្នាំទៅក្នុងការកាត់ទោសគាត់ ប្រសិនបើរកឃើញថាមានទោស។ លោក អាឡិចហ្សាន់ដ្រូ ហ្គន់ហ្សាឡេស ដាវីដសុន (Alejandro Gonzalez-Davidson) ជនជាតិអេស្ប៉ាញ ដែលជាស្ថាបនិកក្រុម និងលោក ស៊ុន រដ្ឋា ក៏ត្រូវបានចោទប្រកាន់ក្រោមច្បាប់ប្រមាថព្រះមហាក្សត្ររបស់កម្ពុជាផងដែរ ពីបទប្រមាថព្រះមហាក្សត្រ បន្ទាប់ពីការនិយាយតាមហ្សូម (Zoom) កាលពីថ្ងៃទី ១៤ ខែឧសភា ឆ្នាំ ២០២១ ត្រូវបានបែកធ្លាយ ។

ទាំងលោកអាឡិចហ្សាន់ដ្រូហ្គន់ហ្សាឡេស ដាវីដសុន និង លោករដ្ឋា មិនបាន

តទៅទំព័រទី១៨

# Trial begins for Mother Nature Cambodia activists on conspiracy charge

PHNOM PENH — The trial against Mother Nature Cambodia, one of the country's last environmental activism groups, kicked off at the Phnom Penh Court of First Instance on the morning of May 29.

Ten environmental activists are on trial for allegedly plotting against the government, a charge that carries a prison sentence of between five and 10 years.



(Left to right) Ly Chandaravuth, Long Kunthea, Phuon Keoreaksmey, Thun Ratha and Yim Leanghy of Mother Nature Cambodia say farewell to supporters before entering the court on May 29, 2024. Image by Gerald Flynn / Mongabay.

Of the 10, only five attended court, dressed in traditional Cambodian burial attire: Yim Leanghy, Ly Chandaravuth, Thun Ratha, Phuon Keoreaksmey and Long Kunthea.



Veteran activist Ouch Pichsamnang hugs Phuon Keoreaksmey of Mother Nature Cambodia before the environmental activists stand trial. Image by Gerald Flynn / Mongabay.

Leanghy is among three Mother Nature Cambodia activists on trial for both plotting against the government and insulting the king.

The second charge could add between one and five years to his sentence if found guilty. Spanish national Alejandro Gonzalez-Davidson, the group's founder, and Sun Ratha were also charged under Cambodia's lèse-majesté laws for insulting the king after a Zoom call from May 14, 2021, was leaked.

Neither Gonzalez-Davidson nor Ratha attended court. Gonzalez-Davidson, the group's original founder, was deported from Cambodia in 2015 and remains banned from entering the country. Three others — Minh Piseth, Rai Raksa and Pok Khoey — were charged with plotting and did not appear before the court.

The start of the trial saw only Leanghy take the stand for questioning, after which the court was adjourned for lunch at 11:30 a.m. Proceedings will pick back up for a full-day hearing on June 5, according to sources from inside the courtroom.

Mother Nature Cambodia's trial has been delayed repeatedly, and there were emotional scenes outside the court as the five activists in attendance braced themselves for a return to prison. Thun Ratha held his infant child until it was time to enter the court.

Outside the court, prior to the trial beginning, Long Kunthea, who faces up to 10 years in prison, protested the innocence of the environmental activism group.

"We are innocent people and we work to protect the national interest," she said. "If today the court decides to accuse us and take us to prison again, we are still thankful to all the people who grant us justice because the court never grant us justice."

The charges of plotting date back from 2012 to 2021 and cover a wide range of Mother Nature Cambodia's activism. Six of the activists, including the five present at court on May 29, already served time behind bars for their activism, but were released on bail on Nov. 12, 2021.

However, the charges were never dropped and the conditions of their bail demanded they cease all activism.

Kunthea had been planning to stage a one-

Please see /18

តមកពីទំព័រទី ០១

# ខ្មែរក្រោមនៅតែមិនមានសិទ្ធិសេរីភាព

ជនជាតិដើមខ្មែរក្រោមពីការរំលោភបំពានរបស់វៀតណាម ពលរដ្ឋខ្មែរ និងខ្មែរក្រោមរំពឹងថានៅថ្ងៃអនាគតពលរដ្ឋខ្មែរក្រោម នឹងទទួលបានសិទ្ធិស្វ័យសម្រេចលើវាសនាខ្លួនដោយខ្លួនឯងការលើកឡើងនេះធ្វើឡើងនៅក្នុងថ្ងៃរំលឹកខួបទី៧៥ឆ្នាំដែលអាណានិគមនិយមបារាំង បានផ្ទេរការគ្រប់គ្រងកម្ពុជាក្រោមឲ្យទៅវៀតណាមត្រួតត្រាបន្តដោយខុសច្បាប់។

សហព័ន្ធខ្មែរកម្ពុជាក្រោម នៅថ្ងៃទី៤ មិថុនា បានចេញសេចក្តីថ្លែងការណ៍ បង្ហាញពីការរំលោភសិទ្ធិមនុស្សខ្មែរក្រោម រយៈពេល៧៥ឆ្នាំ ក្រោមការគ្រប់គ្រងរបស់វៀតណាម ដែលរួមមានការប៉ុនប៉ងរំលាយវប្បធម៌ សាសនា និងបំបិទសិទ្ធិបញ្ចេញមតិពលរដ្ឋខ្មែរក្រោមជាដើម។ សហព័ន្ធបញ្ជាក់ថា កត្តាទាំងនេះហើយដែលធ្វើឲ្យពលរដ្ឋខ្មែរក្រោម ក្រោកឡើងតស៊ូមតិជាមួយរដ្ឋាភិបាលវៀតណាម នៅលើឆាកអន្តរជាតិ ដើម្បីទាមទារសិទ្ធិស្វ័យសម្រេចវាសនាដោយខ្លួនឯង។ សហព័ន្ធខ្មែរកម្ពុជាក្រោម ស្នើឲ្យរដ្ឋាភិបាលវៀតណាម ក្នុងនាមជាសមាជិក នៃក្រុមប្រឹក្សាសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិត្រូវតែគោរពនូវការប្តេជ្ញាចិត្តរបស់ខ្លួន និងគោរពសិទ្ធិសេរីភាពមូលដ្ឋានរបស់ពលរដ្ឋខ្មែរក្រោមតាមសន្ធិសញ្ញាដែលវៀតណាមបានចុះហត្ថលេខាជាមួយអង្គការសហប្រជាជាតិ។

កាលពីថ្ងៃទី៤ ខែមិថុនា ឆ្នាំ១៩៤៩ អាណានិគមនិយមបារាំងបានកាត់ទឹកដីកម្ពុជាក្រោម ទៅឱ្យវៀតណាមត្រួតត្រាបន្តដោយខុសច្បាប់រហូតមកទល់ពេលបច្ចុប្បន្ននេះ។នៅក្នុងរយៈពេល៧៥ឆ្នាំនេះ ខ្មែរក្រោម ដែលរស់នៅលើទឹកដីកំណើតរងការធ្វើទុក្ខបុកម្នេញសព្វបែបយ៉ាង ពីសំណាក់អាជ្ញាធរវៀតណាម ដែលរកគ្រប់មធ្យោបាយដើម្បីបំបាត់អត្តសញ្ញាណវប្បធម៌ប្រពៃណី និងសាសនាខ្មែរក្រោម។ បច្ចុប្បន្នមានសកម្មជនខ្មែរក្រោម ចំនួន៨នាក់ និងព្រះសង្ឃ ៥អង្គ ត្រូវបានអាជ្ញាធរវៀតណាមចាប់ឃុំឃាំងក្នុងពន្ធនាគារ ដោយសារតែការផ្សព្វផ្សាយពីសិទ្ធិមនុស្ស សិទ្ធិជនជាតិដើម និងទាមទារសិទ្ធិស្វ័យសម្រេចសម្រាប់ពលរដ្ឋខ្មែរក្រោម។

នៅថ្ងៃនេះដែរនៅឯដែនដីកម្ពុជាក្រោមវិញ ព្រះសង្ឃ និងពលរដ្ឋខ្មែរក្រោម រាប់រយអង្គ/នាក់ បានជួបជុំគ្នាប្រារព្ធពិធីរំលឹកខួបនេះ នៅវត្តពោធិច្ចឡាមណី ព្រះចេតិយ នៅក្នុងស្រុកថ្កូវ ខេត្តព្រះត្រពាំង។

ក្នុងពិធីនេះ ព្រះសង្ឃបានសូត្រមន្តសម្តែងធម្មទេសនា និងសម្តែងមតិទាក់ទងនឹងប្រវត្តិសាស្រ្តទឹកដីខ្មែរកម្ពុជាក្រោម។

នៅព្រឹកថ្ងៃទី ៤ មិថុនា អាជ្ញាធរវៀតណាម បានឃាត់ពលរដ្ឋខ្មែរក្រោមមួយចំនួន ដើម្បីសួរនាំពួកគេរឿងធ្វើដំណើរទៅចូលរួមកម្មវិធីរំលឹកខួបលើក៧៥ឆ្នាំនេះ។

ព្រះសង្ឃសកម្មការងារសង្គម ព្រះតេជព្រះគុណ ធូ វ៉ាឃីម រំពឹងថា ពលរដ្ឋខ្មែរកម្ពុជាក្រោមនៅតែបន្តសកម្មភាពតស៊ូមតិដើម្បីទាមទារឲ្យអាជ្ញាធរវៀតណាម គោរពសិទ្ធិសេរីភាព និងការពារវប្បធម៌



លោក រ៉ុង ឈុន នៅទីស្នាក់ការកណ្តាលគណបក្សកម្លាំងជាតិ

និងអក្សរសាស្រ្តនៅលើទឹកដីកម្ពុជាក្រោម។ ព្រះតេជព្រះគុណ ធូ វ៉ាឃីម៖ " អាត្មាមានក្តីរំពឹងមួយថា ពួកគាត់នឹងតស៊ូរហូត គាត់មិនអាចចុះចាញ់ ឬនៅស្ងៀមបានទេ ព្រោះអាត្មាចង់ឲ្យពួកគាត់តស៊ូទាមទាររកសិទ្ធិសេរីភាពរបស់ពួកគាត់ ឬទាមទារទឹកដីរបស់គាត់ក៏ថាបាន " ។

ចំណែកឯនៅកម្ពុជាឯណោះវិញ គណបក្សកម្លាំងជាតិ និងគណបក្សប្រជាធិបតេយ្យមូលដ្ឋាន បានចេញសេចក្តីថ្លែងការណ៍ បង្ហាញការឈឺចាប់ និងស្តាយស្រណោះចំពោះការបាត់បង់ទឹកដីកម្ពុជាក្រោម។ គណបក្សទាំងពីរនេះអំពាវនាវដល់រដ្ឋាភិបាលកម្ពុជា ការពារសិទ្ធិពលរដ្ឋខ្មែរក្រោម ដែលមានឈាមជ័រជាខ្មែរតែមួយ និងទាមទារឲ្យវៀតណាម គោរពសិទ្ធិសេរីភាពជាមូលដ្ឋាន និងសិទ្ធិជនជាតិដើមខ្មែរក្រោម ព្រមទាំងបញ្ឈប់ការធ្វើទុក្ខបុកម្នេញលើពលរដ្ឋ សកម្មជនសិទ្ធិមនុស្ស និងព្រះសង្ឃខ្មែរក្រោមបន្តទៀត។

ទីប្រឹក្សាគណបក្សកម្លាំងជាតិ លោក រ៉ុង ឈុន សម្ភាសន៍នៅវិទ្យុអាស៊ីសេរី នៅថ្ងៃទី៤ មិថុនា ថា គណបក្សកម្លាំង

តទៅទំព័រទី១១

# Khmer Krom People Do Not Have Freedom Under Vietnamese Rule

From Page 01

Vietnam. Khmer Krom people expect that in the future, Khmer Krom people will have the right to decide their own destiny. This statement was made on the 75th anniversary of the French colonial transfer of control of Kampuchea Krom to Vietnam illegally.

The Khmer Krom Federation on June 4 issued a statement highlighting the 75 years of Khmer Krom human rights violations under Vietnamese rule, including attempts to eradicate the Khmer Krom culture and religion and suppress the freedom of expression of the Khmer Krom. The federation states that these are the factors that make the Khmer Krom people stand up and advocate with the Vietnamese government on the international stage to demand the right to self-determination. The Khmer Kampuchea Krom Federation urges the Vietnamese government, as a member of the UN Human Rights Council, to respect its commitments and respect the fundamental rights of the Khmer Krom in accordance with the treaty that Vietnam has signed with the United Nations.

On June 4, 1949, the French colony ceded Kampuchea Krom to Vietnam illegally which continues to this day. During these 75 years, the Khmer Krom people living in their own homeland have been subjected to all kinds of persecution by the Vietnamese authorities, who have sought every means to eradicate the Khmer Krom cultural, traditional and religious identity. Currently, eight Khmer Krom activists and five monks have been detained by Vietnamese authorities for promoting human rights, indigenous rights, and the right to self-determination.

Today, in Kampuchea Krom, hundreds of monks and Khmer-Krom people gathered to celebrate this anniversary at Wat Po Cholamani, at a stupa in Tra Cu district, Preah Trapeang province. In this ceremony, the monks prayed, delivered sermons and spoke about the history of the Khmer Kampuchea Krom territory.

In the morning of June 4, Vietnamese authorities detained some Khmer Krom citizens for questioning as they traveled to attend the 75th anniversary commemoration.

Social activist monk Thou Vakhim expects the Khmer Krom people to continue their advocacy activities to demand that the Vietnamese authorities respect the rights and freedoms and protect the culture and literature in Kampuchea Krom. Venerable Thuva Khim said: "I have an expectation that they will fight, they will not give up or remain silent, because I want them to fight for their rights or their land."

In Cambodia, meanwhile, the National Forces Party and the Local Democrat Party have issued statements expressing pain and regret over the loss of Kampuchea Krom territory. Both parties call on the Cambodian government to protect the rights of Khmer Krom citizens of the same Khmer blood and to demand that Vietnam respect fundamental freedoms and rights of the Khmer Krom, as well as end the persecution of its citizens, human rights activists and monks.

Rong Chhun, an adviser to the National Forces Party, told RFA on June 4 that the National Forces Party will not standstill folding its hands and let any Cambodian suffer.

Mr. Rong Chhun said: "As I am a Khmer, as well as the National Forces Party, we do not standstill and watch the Khmer Krom, we are Khmer Krom, Khmer Kandal, Khmer Leu, Khmer in the world, we are the same Khmer in the world suffering abuse, the National Forces Party will advocate and seek freedom."

This statement is in line with the views of Rong Chhun, an adviser to the National Forces Party, on VOD Radio, where Rong Chhun wants to see Cambodian leaders talk to Vietnamese leaders about the harassment of Khmer Krom rights with respect to religious beliefs. Khmer scholars respect the Khmer tradition, like the current arrest of monks and advocates to prison, so far, no release. "The National Forces Party demands the Vietnamese authorities reconsider and must give freedom to monks as well as activists."

Mr. Taing Sarak, Regional President of the Khmer Kampuchea Krom Federation in Cambodia, said: "the territory

Please see /11



# ពេលដែលកងកម្លាំងអ៊ុយក្រែនផ្តើមវាយបករុស្ស៊ីវិញម្តង

អឺរ៉ុប ទី១មិថុនា២០២៤

ក្នុងអម្លុងពេលដែលរដូវរងារចុងឆ្នាំ២០២៣មកដល់ កងទ័ពលោកវូឡូឌីមៀ ជេឡិនស្គី បាននៅជាប់គាំងនឹងកន្លែង រើមិនរួច ដោយខ្វះអាវុធយុទ្ធភណ្ឌសម្រាប់ទប់ទល់នឹងខ្មាំង ហើយដែលរុស្ស៊ីវាយលុក បាញ់គ្រាប់ប្លោង មិនស្រាកស្រាន្ត ហើយយកបានតំបន់យុទ្ធសាស្រ្តដ៏សំខាន់មួយបានគឺ អាឌីវស្កា។ អាវុធសំខាន់ៗរបស់អ៊ុយក្រែនមានសម្រាប់វាយបករុស្ស៊ីនារដូវរងារកន្លងទៅគឺ«ដ្រូន»ធ្វើអាយដ៏មានប្រសិទ្ធិភាព នឹងគ្រាប់មីស៊ីលតិចតួចដែលនៅសល់ ហើយនឹងទឹកចិត្តមុះមុត ដែលខឹតខំការពារមាតុភូមិយ៉ាងស្វិតស្វាញ តែម្យ៉ាងប៉ុណ្ណោះ។ ទំនាស់នៅសភាអាមេរីកាំង បានធ្វើឲ្យយឺតយ៉ាវដល់ការផ្គត់ផ្គង់អាវុធ នឹងថវិកាដល់អ៊ុយក្រែន អស់ពេល៦ខែ យ៉ាងគួរឲ្យព្រួយបារម្ភជាទិបំផុត ជាពិសេសទៅទៀតនោះគឺប្រទេសនៃសម្ព័ន្ធ«អូតង់»មិនហ៊ានធ្វើអ្វីខុសពីសហរដ្ឋអាមេរីកទេ គឺមិនបានផ្តល់ជំនួយអ្វី ឲ្យទៅអ៊ុយក្រែនដូចគ្នា ។




តែកាលពីខែឧសភាមុននេះ សភាអាមេរីកក៏ស្រាប់តែព្រមទម្លាក់ជំនួយជាង៦០ពាន់លាន មកឲ្យអ៊ុយក្រែនបាន រីឯអឺរ៉ុបក៏ធ្វើតាមភ្លាមដែរ, អាវុធ ធុនតូច ធំ បានមកដល់ រថពាសដែល គ្រាប់មីស៊ីល បាញ់បានឆ្ងាយ សម្ភារការពារដែនអាកាស ក៏មកដល់ រីឯយន្តហោះប្រដេញ ក៏សន្យាថានឹងមកដល់ដែរ។ អ៊ុយក្រែនក៏មានលទ្ធភាពភ្លាម វាយយកដែនដីខ្លះបានមកវិញ បានជាច្រើនពាន់គ.ម.ក្រឡា នៅភាគខាងជើង ធ្វើឲ្យរុស្ស៊ីដកថយចេញពីតំបន់ យាប៉ូរីហ្ស្យា ដុងបាស ។ លើកនេះ ភាពក្រអឺតក្រទមរបស់ពូទីន ដែលថា«អាចនឹងប្រើអាវុធនុ្យក្លេអ៊ែ»បាន ត្រូវសហរដ្ឋអាមេរីកអនុញ្ញាត្តិបន្ថែម«ឲ្យអ៊ុយក្រែនប្រើអាវុធខ្លួន វាយចូលដែនដីរុស្ស៊ីវិញបាន ទៅលើគោលដៅយោធាដែលនៅម្តុំក្រុងគៀវ», ចំណែកអូតង់ក៏ធ្វើតាមដូចគ្នាភ្លាមទៀត ដែលលោកជេឡិនស្គី ឧទ្ទានភ្លាមៗថា«នេះគឺជាលទ្ធភាពកាន់តែច្រើនឡើងរបស់ក្រុងគៀវ»។

ខាងក្រោមនេះ គឺជាប្រទេសលោកសេរី ដែលបានជួយដល់ អ៊ុយក្រែនច្រើនជាងគេ ដែលមាន៖ ១ ជំនួយយោធា ពណ៌ខៀវ, ២ ជំនួយថវិកាជាតិពណ៌បៃតង ៣ ជំនួយមនុស្សធម៌ ពណ៌ក្រហម នឹងនៅមានប្រទេសច្រើនទៀត ដែលមិននៅក្នុងបញ្ជី ផ្ទាប់ជមួយនេះទេ ។

ជំនួយបានមកដល់អ៊ុយក្រែនយឺត

តទៅទំព័រទី១៧



**Lowell Primary Care Center**

**មណ្ឌលថែទាំសុខភាព Lowell**

1075 Westford Street, Unit 204
Lowell, MA 01851 • (978) 455-7992

**Lynn Primary Care Center**

**មណ្ឌលថែទាំសុខភាព Lynn**

280 Union Street, Unit 402
Lynn, MA 01901 • (781) 780-7755



Chhan Touch, FNP-BC
ឆាន់ ទូច



Practice Manager
Channa Khan, CMA
អ្នកគ្រប់គ្រងគ្រូពេទ្យ
ចាន់ណា ខាន់



Sophor Chhour, LMHC
សុភ័រ ឈួ



Nalyne Dom, FNP-BC
ណាលីន ដំ



Nida Lam, FNP-BC
នីដា ឡាម



Maredy Sar, DNP, NP-C
ម៉ារីឌី ស



Miadette Pheng-Phal, DNP, NP-C
មីយ៉ាដេត ផេងផល

**Now Accepting New Patients**

ឥឡូវនេះ បើកទទួលអ្នកជំងឺថ្មី

*Family Medicine*
*ថែទាំសមាជិកគ្រួសារ*

*Behavioral Health*
*ថែទាំសុខភាពផ្លូវចិត្ត*

**We Accept MassHealth, Medicare and Other Health Insurances**
**Our Staff Speaks Khmer**

យើងទទួល MassHealth Medicare និងការធានារ៉ាប់រងសុខភាពផ្សេងៗ
បុគ្គលិករបស់យើងនិយាយភាសាខ្មែរ




# ប្រធានាធិបតីអ៊ីរ៉ង់ស្លាប់ក្នុងព្រឹត្តិការធ្លាក់ឧទ្ធម្ភាគចក្រ

អឺរ៉ុប ថ្ងៃទី០២មិថុនា២០២៤

ឧទ្ធម្ភាគចក្រមួយគ្រឿង របស់ប្រធានាធិបតីអ៊ីរ៉ង់ អ៊ីប្រាហ៊ីម រ៉ាយស៊ី បានធ្លាក់នៅជ្រលងភ្នំ ព្រំប្រទល់ជាមួយប្រទេសអាហ្សេបាយហ្សង់ នៅពេលដែលឧទ្ធម្ភាចក្រនោះចេញពីទីសម្ពោធទំនប់ទឹកអាហ្សេបាយហ្សង់មួយ នៅខាងជើងនៃប្រទេសអ៊ីរ៉ង់ កាលពីថ្ងៃទី១៩ឧសភា ក្នុងនោះមានដឹកប្រធានាធិបតីអ៊ីរ៉ង់ រដ្ឋមន្ត្រីការបរទេស ចៅហ្វាយក្រុងអាយាបាយហ្សង់ខាងកើត នឹងរួមទាំងបុគ្គលិក មានអ្នករងគ្រោះទាំងអស់៩រូប។ បន្ទាប់ពីស្វែងរកយ៉ាងអស់សង្ឃឹម អស់រយៈពេល១៥ម៉ោង បានរកឃើញកំទេចឧត្តម្ភាកចក្រឆេះខ្មួច ពុំមានសញ្ញាអ្វីថាមាននរណាម្នាក់រួចជីវិតឡើយ។ ការបាត់បង់វរៈជនដ៏សំខាន់របស់អ៊ីរ៉ង់នាពេលនេះ គឺជាព្រឹត្តិការសំខាន់បំផុតមួយ នៅក្នុងតំបន់ នឹងក្នុងពិភពលោក ពីព្រោះតែសង្គ្រាមនៅមជ្ឈឹមបូព៌ា រវាងក្រុមតស៊ូអ៊ីស្លាមទាំងអស់ តទល់នឹងអ៊ីស្រ្តាអែល សុទ្ធសឹងមានស្នាដៃរបស់ប្រទេសអ៊ីរ៉ង ដឹកនាំដោយលោក រ៉ាយស៊ីស នេះទាំងអស់។ ការបាត់បង់នេះ បានទទួលការសោកស្តាយពិក្រុមប្រទេសអ៊ីស្លាម ក្រុមភេរវកម្មអេបូឡា ក្រុមហាម៉ាស់ ហើយក៏មានដំណាងអ.ស.ប.នឹង«អូតង់»ផងដែរ, ដំណែងរបស់លោក នឹងត្រូវដឹកនាំបន្តរដោយលោកអនុប្រធានាធិបរតីអ៊ីរ៉ង់ មហាម៉េត មោកប៊ី ។

លោក អ៊ីប្រាហ៊ីម រ៉ាយស៊ីស អាយុ៦៣ឆ្នាំ បានជាប់ឆ្នោតឡើងជាប្រធានាធិបតី កាលពី៣ឆ្នាំមុន ប្រកាន់នយោបាយតឹងតែងអភិរក្សនិយមចំពោះអ្នកសិក្សា ហើយនឹងអ្នកនយោបាយប្រឆាំង។ លោកមានឋានៈជា«អាយ៉ាតុឡា» ដែលជាអាចារ្យធំជាងគេបង្អស់ក្នុងឋានន្តរសក្តវិហ៊ារអ៊ីស្លាម ហើយក៏ជាមនុស្សដែល សំណប់ចិត្តបំផុតរបស់ប្រមុខរដ្ឋ អាលី ខាមេនី ក្នុងចំណោមប្រធានាធិបតីទាំងអស់ដែលកាន់ដំណែងពីមុនមក ហើយក៏អាចជាអ្នកបំរុងស្នងដំណែងប្រមុខរដ្ឋអ៊ីរ៉ង់ បានទៀតផង។

ប្រទេសអ៊ីរ៉ង់ជាប្រទេសដែលជួយឧបត្ថម្ភដល់អង្គភាពសកម្មនៃភេរវកម្មជាច្រើន ដែលប្រតិបត្តិការនៅជុំវិញពិភពលោក គ្រុមដែលនៅជិតជាងគេមានអេបូឡា នៅលីបង់, មានក្រុមហាម៉ាស់ នៅគ្គាស្ហា, នឹងមាន ក្រុមអាល់ខៃដា ឬជីហាដនៅឆ្ងាយបន្តិចតែមាន






លោក អ៊ីប្រាហ៊ីម រ៉ាយស៊ី ប្រធានាធិបតី ស្លាប់ក្នុងគ្រោះថ្នាក់ឧទ្ធម្ភាកចក្រ

ទំនាក់ទំនងសម្ងាត់ មិនដែលដាច់, ទាំងនោះ គឺដើម្បីបុព្វហេតុសាសនាអ៊ីស្លាម ប្រឆាំងនឹងប្រទេសលោកសេរី ។ ប្រទេសអ៊ីស្រ្តាអែល ជាប្រទេសដែលប្រកបដោយគ្រោះថ្នាក់ធំជាងគេ ដោយមានសាសនាខុសពីប្រទេសនៅជុំវិញខ្លួន ដែលមានភូមិសាស្រ្តនៅចំកណ្តាលប្រទេសអ៊ីស្លាមទាំងអស់ថែមទៀត ដូចជា ប្រទេសលីបង់ អ៊ីរ៉ង់ អ៊ីរ៉ាក់ ប្រទេសអេជីប ឬប៉ាឡេស្ទីន ជាដើម។ ហេតុនោះហើយបានជាគ្មានប្រទេសនៅជាប់របងគ្នាណា ចង់ឲ្យអ៊ីស្រ្តាអែលរស់នៅទីដដែលនោះទេ,ប៉ុន្តែទាស់តែអ៊ីស្រ្តាអែល ជាប្រទេសមានកម្លាំងគ្រប់គ្រាន់ ចេះការពារខ្លួន នឹងមានប្រទេសសេរីធំៗ នៅការពារយ៉ាងប្រកៀកជានិច្ច មិនអាចឲ្យសម្ពន្ធអ៊ីស្លាមធ្វើអ្វីបានឡើយ។

ការបាត់បង់លោក អ៊ីប្រាហ៊ីម រ៉ាយស៊ី ចំពេលដែលនៅគ្គាស្ហា ក្រុមហាម៉ាស់កំពុងតែត្រូវរងការវាយប្រហារយ៉ាងខ្លាំងខ្លា ពីសំណាក់កងទ័ពអ៊ីស្រ្តាអែល ឬក៏នៅប្រទេសស៊ីរី ពុំទាន់បានបញ្ឈប់សង្គ្រាមស្រួលបួលផងនោះម្យ៉ាង,ហើយម្យ៉ាងទៀត អ៊ីរ៉ង់ ត្រូវជួយជាសម្ភារៈចម្បាំងដល់ប្រទេសរុស្ស៊ី ដែលកំពុងខ្វះខាតអាវុធ, ដូច្នេះអាចធ្វើឲ្យគម្រោងទាំងឡាយសម្រាប់ទប់ទល់នឹងបច្ចឹមលោកខូចខាតរលត់រលាយអស់ បើនយោបាយរបស់អ៊ីរ៉ង់ត្រូវប្តូរផ្លាស់ ដោយមានប្រមុខដឹកនាំថ្មី ទៅអនាគត... នៅ៥០ថ្ងៃខាងមុខនោះ រដ្ឋធម្មនុញ្ញអ៊ីរ៉ង់តម្រូវឲ្យមានការបោះឆ្នោតមួយ សម្រាប់តែងតាំងប្រធានាធិបតីថ្មី ជំនួសលោករ៉ាយស៊ី៕






# ព្រឹទ្ធសមាជិកសភា ប្រោន (Brown) ព្រមានរដ្ឋបាលថា ការផ្តល់លក្ខខ័ណ្ឌសេដ្ឋកិច្ចទីផ្សារវៀតណាមនឹងគំរាមកំហែង ដល់កម្មករ និងក្រុមហ៊ុនផលិតរដ្ឋ OHIO ចំណេញដល់ប្រទេសចិន

**ថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៤**

**ប្រទេសចិនប្រើប្រាស់វៀតណាម ដើម្បីគេចការបង់ពន្ធ ធ្វើឲ្យប៉ះពាល់ដល់កម្មកររដ្ឋ ohio**

ទីក្រុងវ៉ាស៊ីនតោន៖សមាជិកព្រឹទ្ធសភាអាមេរិក Sherrod Brown (បក្សប្រជាធិបតេយ្យ-រដ្ឋ Ohio) និងសហការីព្រឹទ្ធសភាមួយក្រុមកំពុងព្រមានរដ្ឋបាលប្រឆាំងនឹងការផ្តល់ឋានៈសេដ្ឋកិច្ចទីផ្សារវៀតណាមដោយប្រាប់រដ្ឋមន្ត្រីពាណិជ្ជកម្ម Gina Raimondo ថាមាន ភស្តុតាងគ្រប់គ្រាន់បង្ហាញថា វៀតណាមមិនបំពេញតាមលក្ខខណ្ឌតម្រូវសេដ្ឋកិច្ចទីផ្សារ និងបង្ហាញការព្រួយបារម្ភយ៉ាងខ្លាំងជាមួយការពិនិត្យឡើងវិញរបស់ក្រសួងពាណិជ្ជកម្មអំពីស្ថានភាពវៀតណាមជាសេដ្ឋកិច្ចមិនមែនទីផ្សារក្រោមច្បាប់ពាណិជ្ជកម្មរបស់សហរដ្ឋអាមេរិក។ ក្រសួងពាណិជ្ជកម្មខ្លួនឯងបានលើកឡើងពីការជូនដំណឹង អំពីការអនុវត្តរបស់ចិនចំពោះប្រទេស វៀតណាម ដើម្បីគេចចេញពីពន្ធអាករលើទំនិញដែលផលិតដោយចិន ដែលជាកាតព្វកិច្ចរបស់សហរដ្ឋអាមេរិក សំដៅលើកម្រិតទីផ្សារ



U.S. Senator Sherrod Brown (D-OH)

ប៉ះពាល់ដល់កម្មកររដ្ឋ Ohio ។

នៅក្នុងលិខិតរបស់ព្រឹទ្ធសភាសរសេរ

**តទៅទំព័រទី១៤**

# BROWN WARNS ADMINISTRATION THAT GRANTING VIETNAM MARKET ECONOMY STATUS WOULD THREATEN OHIO WORKERS & MANUFACTURERS, BOOST CHINA

China Uses Vietnam to Avoid Tariffs that Level the Playing Field for Ohio Workers

WASHINGTON, D.C. – U.S. Senator Sherrod Brown (D-OH) and a group of Senate colleagues are warning the Administration against granting Vietnam market economy status, telling Secretary of Commerce Gina Raimondo that there is significant evidence suggesting Vietnam does not meet the requirements to be designated a market economy and expressing significant concerns with the Department of Commerce's review of Vietnam's status as a nonmarket economy under U.S. trade law. The Commerce Department itself has raised the alarm about China's use of Vietnam to circumvent U.S. antidumping duties on Chinese-made products – duties which are meant to level the playing field for Ohio workers.

"There is abundant evidence suggesting that Vietnam does not meet the legal requirements established by Congress to receive market economy status. We are especially concerned by reports that Commerce pledged to the government of Vietnam that your agency's review will result in a favorable determination, to the detriment of U.S. industries and workers. We urge Commerce to examine the full range of evidence as it conducts its review and to consider the impact on American jobs and producers in its final determination," wrote the senators in their letter.

"Granting Vietnam market economy status before it addresses its clear nonmarket behavior and the severe deficiencies in its labor law will worsen ongoing trade distortions, erode the U.S. manufacturing base, threaten American workers and industries, and reinforce Vietnam's role as a conduit for goods produced in China with forced labor. We urge you and your agency to thoroughly consider the economic and labor conditions in Vietnam as you conduct your review of Vietnam's market economy status, and

**Please see /14**








# បទវិភាគ៖ តើប៉ាឡេស្ទីន អាចក្លាយជាសមាជិកពេញសិទ្ធិនៃអង្គការសហប្រជាជាតិបានដែរឬទេ?

មហាសន្និបាតអង្គការសហប្រជាជាតិកាលពីថ្ងៃសុក្រ ទី១០ ខែឧសភា បានបោះឆ្នោតក្នុងសំឡេងគាំទ្រភាគច្រើនលើសលប់លើសំណើចង់ក្លាយជាសមាជិកអង្គការសហប្រជាជាតិពេញសិទ្ធិរបស់ដែនដីប៉ាឡេស្ទីន នៅតំបន់មជ្ឈិមបូព៌ា។

ទីភ្នាក់ងារសារព័ត៌មាន Reuters បានរាយការណ៍មកថា នៅក្នុងចំណោមសមាជិកមហាសន្និបាតអង្គការសហប្រជាជាតិ ១៩៣ មានចំនួន ១៤៣ប្រទេសបានបោះឆ្នោតគាំទ្រឱ្យប៉ាឡេស្ទីន ចង់បានជាសមាជិកពេញសិទ្ធិរបស់ស្ថាប័នពិភពលោកមួយនេះ ខណៈប្រទេសចំនួន ៩ ក្នុងនោះរួមមានសហរដ្ឋអាមេរិក និងអ៊ីស្រាអែល បានបោះឆ្នោតជំទាស់ និង ២៥ទៀតបោះឆ្នោតអនុបវាទ។

ទោះជាយ៉ាងណា ការបោះឆ្នោតក្នុងសំឡេងគាំទ្រលើសលប់នេះ មិនអាចផ្តល់ឱ្យប៉ាឡេស្ទីន នូវសមាជិកពេញសិទ្ធិរបស់អង្គការសហប្រជាជាតិបានទេ តែវាបានបង្ហាញថា ប្រទេសភាគច្រើនលើសលប់បានទទួលស្គាល់រដ្ឋប៉ាឡេស្ទីន មួយដែលគួរតែទទួលបានឋានៈជាសមាជិកភាពរបស់ស្ថាប័នពិភពលោកមួយនេះ។ តែ




ទន្ទឹមនឹងគ្នានេះ ប៉ាឡេស្ទីន ត្រូវរង់ចាំអនុសាសន៍ពីក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិជាថ្មីម្តងទៀត។ នេះបើយោងតាមក្រឹត្យក្រមធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ។

យោងតាមធម្មនុញ្ញអង្គការសហប្រជាជាតិ ជំពូក៥ ស្តីពីមុខងារ, សិទ្ធិសម្រេច និង

តទៅទំព័រទី១៩

# Analysis: Can Palestine become a full member of the United Nations?

**May 14, 202**

The United Nations General Assembly on Friday voted overwhelmingly in favor of a Palestine proposal to become a full member of the United Nations in the Middle East.

Of the 193 members of the 193-nation General Assembly, 143 voted in favor of Palestine as a full member of the world body, Reuters reported. Israel voted against and 25 abstained.

However, this overwhelming vote did not give Palestine the full membership of the United Nations, but it did show that most countries have recognized a Palestinian state that deserves its membership for this global institution. At the same time, Palestine must once again await UN Security Council recommendations, according to the UN Charter.

According to the UN Charter, Chapter 5 on the functions, decision-making and voting rights of the Security Council, vetoes or objections are the status quo of the respective countries.

The full membership of the United Nations requires the prior approval of the members of the 15-nation Security Council, which is then handed over to the General Assembly for re-election.

Many times, Palestinian efforts have failed due to the opposition of the United States, an ally of Israel.

In fact, in April, the US representative at the United Nations voted against granting full membership to Palestine, arguing that this was not an effective way to push for a two-state solution.

In principle, applications for full UN membership must first be approved by the Security Council, the world's highest decision-making body. In the case of Palestine, the General Assembly alone

Please see /15






តមកពីទំព័រទី ០៤

# ខ្មែរក្រោមនៅតែមិនមានសិទ្ធិសេរីភាព

ជាតិ មិនឈរអោបដៃ ទុកឲ្យខ្មែរណាម្នាក់រងទុក្ខនោះឡើយ។

លោក រ៉ុង ឈុន៖ «ក្នុងនាមខ្ញុំជាខ្មែរមួយរូប ក៏ដូចជាគណបក្សកម្លាំងជាតិ យើងមិនឈរអោបដៃមើលបងប្អូនខ្មែរក្រោមទេ យើងទុកខ្មែរក្រោម ខ្មែរកណ្តាល ខ្មែរលើ ខ្មែរនៅលើពិភពលោក គឺខ្មែរតែមួយឲ្យតែខ្មែរនៅទេណាទទួលរងទុក្ខការរំលោភបំពាន គណបក្សកម្លាំងជាតិនឹងធ្វើការតស៊ូមតិ និងស្វែងរកសិទ្ធិសេរីភាព»។

ការលើកឡើងនេះដូចគ្នាទៅនឹងការយល់ឃើញរបស់ទីប្រឹក្សាគណបក្សកម្លាំងជាតិ លោក រ៉ុង ឈុន ជាមួយនឹងវិទ្យុ VOD ដែល លោក រ៉ុង ឈុន ចង់ឃើញមេដឹកនាំកម្ពុជាជជែកជាមួយមេដឹកនាំវៀតណាម ជុំវិញបញ្ហាយាយីលើសិទ្ធិខ្មែរក្រោម ខាងគោរពជំនឿសាសនានេះ "អក្សរសាស្ត្រខ្មែរ គោរពប្រពៃណីរបស់ខ្មែរ មិនដូចថាបច្ចុប្បន្នចាប់ព្រះសង្ឃ អ្នកតស៊ូមតិទៅដាក់ពន្ធនាគាមកដល់អីឡូវនេះមិនទាន់មានការដោះលែង ហើយគណបក្សកម្លាំងជាតិអោយអាជ្ញាធរយួនត្រូវពិនិត្យពិចារណាឡើងវិញត្រូវតែផ្តល់សេរីភាពដល់ព្រះសង្ឃក៏ដូចជាសកម្មជន"។

លោក តាំង សារ: ប្រធានតំបន់នៃសហព័ន្ធខ្មែរកម្ពុជាក្រោមប្រចាំកម្ពុជា បានមានប្រសាសថា"ទឹកដីព្រះរាជាណាចក្រកម្ពុជា នៅកម្ពុជាក្រោម គឺស្ថិតនៅក្រោមការគ្រប់គ្រង និងត្រួតត្រារបស់អាជ្ញាធរឬរាជរដ្ឋាភិបាលវៀតណាមអាស្រ័យអាណានិគមន៍បារាំង គេបានផ្ទេរសិទ្ធិឲ្យទៅវៀតណាមកាន់កាប់ ដើម្បីឲ្យខ្មែរកម្ពុជាក្រោម ក៏ដូចជាខ្មែរទូទៅជំនាន់ក្រោយមិនចាំ ឬមិនរំឭកពីការបាត់បង់នោះគិតថាជាដីរបស់វៀតណាមបាទនោះជាគោលបំណង និងគោលដៅយ៉ាងនេះឯង".

លោក សឺន ជុំជួន អគ្គលេខធិការសមាគមន៍ខ្មែរកម្ពុជាក្រោមដើម្បីសិទ្ធិមនុស្ស និងការអភិវឌ្ឍន៍ បានលើកឡើង យើងមានគោលបំណងសំខាន់ៗមួយចំនួនឲ្យបងប្អូន ជាពិសេសប្រជាពលរដ្ឋខ្មែរយើង ដែលមកចូលរួមទាំងខ្មែរក្រោម ខ្មែរកណ្តាល និងខ្មែរលើ ថាកម្ពុជាក្រោមថ្ងៃនេះខួប ៧៥ឆ្នាំ ដែលត្រូវបានអាណានិគមន៍បារាំងកាត់ដីរបស់ខ្មែរយើង ឲ្យទៅវៀតណាមកាន់កាប់ផងទី២ដើម្បីរំលឹកឲ្យមានការភ្ញាក់រលឹកឡើង

វិញពីឧត្តមគតិរបស់ខ្មែរយើងដើម្បីទាមទារសិទ្ធិសេរីភាពរបស់កម្ពុជាក្រោម ឲ្យមានសមនសិការរឭកឡើងវិញចូលរួមសកម្មភាពទាំងអស់គ្នា។

លោកស្រី ចៅ រតនៈ ក្រុមប្រឹក្សាសង្កាត់ប៉ោយប៉ែតបាននិយាយថា យុវជនខ្មែរក្រោម ខ្មែរកណ្តាល ខ្មែរលើ ត្រូវតែចូលរួមដឹងការឈឺចាប់របស់ខ្មែរកម្ពុជាក្រោម គឺយើងមិនត្រូវភ្លេចខ្មែរក្រោមទេ ព្រោះអីជាខ្មែរតែមួយ ឌូច្នេះសូមបងប្អូនកុំបែងចែកកុំរើសអើងវណ្ណៈខ្មែរក្រោម ខ្មែរលើ ខ្មែរកណ្តាល ចា! យ៉ងជាខ្មែរតែមួយទាំងអស់គ្នាហើយសង្ឃឹមថាពុកម៉ែបងប្អូនទូទាំងពិភពលោកត្រូវទទួលស្គាល់ថាខ្មែរកម្ពុជាគឺជាខ្មែរតែមួយទាំងអស់គ្នា។



លោក សឺន សុប៊ែរ កំពុងមើលរូបភាពអ្នកតស៊ូខ្មែរត្រូវបានវៀតណាមចាប់ដាក់គុក

ចំណែកលោក ប៉ែន បូណា ប្រធានអង្គភាពអ្នកនាំពាក្យរដ្ឋាភិបាល និងស្ថានទូតវៀតណាមប្រចាំនៅកម្ពុជា មិនបានផ្តល់បទសម្ភាសន៍អោយ វិទ្យុអាស៊ីសេរី VOD ឬពត៌មានឯករាជ្យផ្សេងទៀត នៅមិនទាន់អាចទាក់ទងបាន ដើម្បីសុំការឆ្លើយតបជុំវិញបញ្ហានេះបាននៅឡើយទេ នៅថ្ងៃទី៤មិថុនា។

ចំណោកឯបក្សក្រៅរដ្ឋាភិបាល យកខួបបាត់បង់ទឹកដីជំរុញឲ្យមេដឹកនាំបក្សកាន់អំណាច យកចិត្តទុកដាក់ពីសុខទុក្ខខ្មែរក្រោម ដែលកំពុងរងការយាយីពីវៀតណាម ជុំវិញជំនឿសាសនា ភ្ជាប់ទៅនឹងសារក្រើនរំលឹកឲ្យពង្រឹងផ្ទៃក្នុងជាតិ ដើម្បីទប់ស្កាត់មហិច្ឆតាលេបទឹកដីបន្ថែមទៀតពីប្រទេសជិតខាងគណបក្សប្រជាធិបតេយ្យនិយាយក្នុងសេចក្តីថ្លែងការណ៍មួយថ្ងៃមុនខួបបាត់បង់ទឹកដីថា នៅថ្ងៃទី០៤ មិថុនា ឆ្នាំ១៩៤៩ ទឹកដីកម្ពុជាក្រោមត្រូវបានសម្រេចផ្ទេរទៅ ឲ្យប្រទេសវៀតណាមត្រួតត្រាតាម

តទៅទំព័រទី២២

# Khmer Krom People Do Not Have Freedom Under Vietnamese Rule

**From Page 04**

of the Kingdom of Cambodia in Kampuchea Krom was under the administration and control of the Vietnamese authorities or the government during the French colony. Vietnamese does not want new Khmer generation to know about the landowner or remember the loss of land to Vietnam. That is the goal."

Mr. Son Chumchoun, Secretary General of the Khmer Kampuchea Krom Association for Human Rights and Development stated that we have some important objectives for you, especially our Khmer people who come to participate, including Khmer Krom, Khmer Kandal and Khmer Leu, that Kampuchea Krom is now 75 years after the French colony cut off our Khmer lands to Vietnam. We commemorate this event for the sake of our Khmer people to demand the rights and freedoms of Kampuchea Krom to raise their consciousness and participate in activities.

Ms. Chao Rattanak, Poipet Sangkat Councilor, said that the Khmer Krom, Khmer Kandal, Khmer Leu youth must be aware of the suffering of the Khmer Kampuchea Krom, we must not forget the Khmer Krom, because we are the only Khmer, so please do not discriminate, do not discriminate the Khmer Leu, Khmer Kandal! We are all one Khmer and hope that parents and siblings all over the world will recognize that we are one Khmer.

Mr. Pen Bona, Head of the Government Spokesperson Unit and the Vietnamese Embassy in Cambodia, could not be reached for comment by VOD or other independent sources on June 4.

Meanwhile, non-ruling political parties commemorated the anniversary of the loss of territory, urging the ruling party leaders to pay attention to the well-being of the Khmer Krom who are being harassed by Vietnam over religious beliefs linked to the message to strengthen the nation to prevent the ambition to swallow more territory from neighboring countries, Democrats Party said in a statement the day before the anniversary of the loss of territory that "on June 4, 1949, the territory of Kampuchea Krom was decided to be transferred to Vietnam under the control of French President Vincent Auriol, according to the party, since then the Khmer Krom have become an indigenous people in the territory. Myself, I would like to express my deepest condolences for the loss of Kampuchea Krom territory, which we will never forget, in which the Khmer Kampuchea Krom people are of the same Khmer blood. The transfer of Kampuchea Krom to Vietnam is a historical lesson that the next generation of Cambodian leaders and Cambodians of all backgrounds must remember and unite. Local Democrats call on the Cambodian government to cooperate with the Vietnam to ensure that the Khmer people have sufficient rights and freedoms, respect for basic human rights, especially cultural, religious and other civil rights, in protest, demand, expression and assembly in accordance with international law, especially the Royal Government of Cambodia to talk with the Vietnamese government to set up consular mission. In addition, there will be regular missions from the Royal Government of Cambodia to areas inhabited by Khmer Kampuchea Krom. That Kampuchea Krom is the only Khmer people that leaders should fulfill this duty, and we also thank the Khmer Kampuchea Krom people. "Despite persecution by the Vietnamese authorities, they are still struggling to preserve the traditional Khmer literary culture."

Ou Chanrath, co-founder of the Cambodian Reform Party and a former CNRP lawmaker, supported the push, emphasizing that telling Vietnam to respect Khmer Krom rights is necessary, as the Vietnamese side often asked Cambodia to protect its people. Who came to live in Cambodia, including illegal immigrants.

"Forgot to think about this for a long time, because even though the Cambodian people themselves do not remind [Vietnam], the Vietnamese government seems to warn because they protect their people on the territory of Cambodia today both legal and illegal. The whole territory of Kampuchea Krom has millions of people living there and the Cambo-

Please see /22

# គណបក្សស្តាំផុតបារាំងឈ្នះដាច់នៅសភាអឺរ៉ុប

អឺរ៉ុប ទី១២មិថុនា២០២៤

នៅថ្ងៃប្រកាសលទ្ធផលឆ្នោតនៅ«សភាសហភាពអឺរ៉ុប»កាលពីថ្ងៃទិ៩មិថុនាមក ប្រធានាធិបតី ម៉ាក្រុង នៃប្រទេសបារាំង បានប្រកាសតាមទូរទស្សន៍«រំលាយសភាបារាំង»មុនអាណត្តិចោល ដោយយោងទៅតាមលទ្ធផលឈ្នះដាច់គេ របស់គណបក្សស្តាំផុតនិយមបារាំង របស់ម៉ារីន ឡឺប៉ិន នៅសភាអឺរ៉ុបនោះ។ លោក ម៉ាក្រុង បានសម្រេចយកថ្ងៃទី៣០មិថុនា ជាថ្ងៃបោះឆ្នោតសភាជុំទី១ នឹងថ្ងៃទី៩កក្កដា ជាថ្ងៃបោះឆ្នោតសភាផ្តាច់ព្រ័ត្រ។ ជោគជ័យនេះ ធ្វើឲ្យអតីតជនភៀសខ្លួនខ្មែរនៅបារាំងគិតយ៉ាងម៉េចដែរ?ប្រសិនបើគណបក្សស្តាំផុតនោះជាប់ឆ្នោតភាគច្រើននៅសភាបារាំង ហើយការបារម្ភរបៀបគ្នានោះ ក៏កំពុងតែរីកធំកើតឡើងដូចគ្នានៅសហរដ្ឋអាមេរិក ប្រសិនបើជាគណបក្សសាធារណរដ្ឋ ស្តាំផុតនិយមរបស់លោក ឌណាល ត្រាំ ជាប់ឆ្នោតជាប្រធានាធិបតីអាមេរិកម្តងទៀត នៅខែវិច្ឆិកា២០២៤ខាងមុខ?

នៅប្រទេសបារាំងក្រុមស្តាំផុតនិយមមិនដែលបានទទួលការគាំទ្រច្រើនយ៉ាងនេះ(បាន៣១,៥%នៅសភាអឺរ៉ុបពេលនេះ)ទេ ប៉ុន្តែដោយសារតែ ក្រុមមួយនេះមាននយោបាយមិនចូលចិត្តជួយពួកអន្តោប្រវេសន៍ មិនចូលចិត្តជួយក្រុមសាសនាមូស្លីម មិនចូលចិត្តពលរដ្ឋមកពិប្រទេសម៉ាក្រេប(អាហ្វ្រិកខាងជើង)ទេ,ពិសេសនោះមិនចូលចិត្តឲ្យរដ្ឋាភិបាលយកថវិការជាតិទៅជួយប្រទេសដ៏ទៃដូចជាទៅជួយប្រទេសអ៊ុយក្រែនជាដើម ធ្វើឲ្យអ្នកប្រកាន់នយោបាយស្តាំកណ្តាលនិយម ឬអ្នកប្រកាន់សង្គមឆ្វេងនិយមមានការមិនពេញចិត្ត ពីព្រោះជាការគ្រោះថ្នាក់ ដល់ភាពវិជ្ជមានអ្វីៗដែលទទួលបានរួចពីមុនមកហើយ។ ក្រុមប្រជាពលរដ្ឋតូចតាច បារម្ភពីស្ថានភាពសង្គមកិច្ច លំនៅឋាន ឬក៏សន្តិសុខរបស់ពួកខ្លួន ត្រូវរងគ្រោះដោយរដ្ឋអំណាចដែលមានអំណាចផ្តាច់ការ រឹងសេរីភាពពលរដ្ឋ ក៏នឹងត្រូវប្រវ័ញ្ញដោយប៉ូលិសឬយោធាប្រដាប់អាវុធ។ ក្រុមស្តាំផុតនិយមបារាំងនោះទៀតសោត មានទំនាក់ទំនងយ៉ាងជិតស្និតជាមួយលោកប្រធានាធិបតីពូទីន នៃប្រទេសរុស្ស៊ី ដែលកំពុងធ្វើសង្គ្រាមឈ្លានពានលើអ៊ុយក្រែន ដែលជាហេតុធ្វើឲ្យគេយល់ថា ភាពសុច្ចរឹតភាពស្មោះត្រង់ នឹងភាពយុត្តិធម្ម នឹងពុំមានទៀតទេ នៅក្នុងរបបស្តាំផុតនិយមដែលអាចនឹងមកដល់នោះ!






ម៉ារីន ឡឺប៉ិន ប្រធានបក្សស្តាំផុតនិយមបារាំង

លោកប្រធានាធិបតី ម៉ាក្រុង នៅពេលប្រកាសរំលាយសភាបារាំង ពុំបានបញ្ជាក់ពីបុព្វហេតុនៃវត្ថុបំណងរបស់លោកនោះទេ ដូច្នោះហើយបានជាមានសំនួរថា ហេតុអ្វីក៏លោកធ្វើឲ្យមានភាពច្រូលច្របល់យ៉ាងនេះ? ពីព្រោះគេមើលឃើញថា ពុំទាន់មានភាពចាំបាច់នៅឡើយទេ ដោយសារ ១ ឥតទាន់មានការគម្រាមកំហែងដល់អំណាចគណបក្សលោកម៉ាក្រុង នឹងសម្ព័ន្ធមិត្តលោក នៅឡើយទេ ២ គណបក្សស្តាំផុតនិយមបារាំង បានឡើងច្រើនមែន ប៉ុន្តែពុំមែនឡើងរហូតដល់ ឲ្យមានរង្គោះរង្គើអំណាចចាស់ នៅពេញអឺរ៉ុបនោះទេ នៅប្រទេសដ៏ទៃ ក្រុមនោះឡើងចំនួនតិចតួចប៉ុណ្ណោះ ៣ ដូច្នេះគេអាចសន្និដ្ឋានថា គឺនយោបាយប្រទេសបារាំងខ្លួនឯង ដែលធ្វើឲ្យគណបក្សស្តាំផុតនិយមនោះលេចធ្លោនៅក្នុងប្រទេសបារាំងបាន។



ប្រធានាធិបតីបារាំង ម៉ាក្រុង



នៅសហរដ្ឋអាមេរិកនៃលោកឌណាល ត្រាំវិញ គេអាចលើកវិរៈភាពនៃគណបក្សស្តាំផុតនិយមបារាំងរបស់ ម៉ារីន ឡឺប៉ិន សម្រាប់ការឃោសនា របស់លោក នៅឯអាមេរិកនោះបាន ប៉ុន្តែភាពស្ងាត់ស្ងៀមរបស់ប្រទេសទាំង៣២ នៃសហភាពអឺរ៉ុបផ្សេងទៀតមិនបានឲ្យតម្លៃនៃទំនាក់ទំនងជាមួយនឹងពូទីននោះទេពីព្រោះ«សហភាពអឺរ៉ុបត្រូវការអាមេរិក ឲ្យនៅជាមួយនឹងពួកគេ»ដូច្នេះពេលនេះគឺគេត្រូវការ«ជោគជ័យរបស់ លោក ជោ បាយដិន» ដើម្បីយកជ័យជំនះឲ្យអ៊ុយក្រែន នឹងឲ្យអឺរ៉ុប ទើបមានសន្តិភាព។

តើបារាំងបានធ្វើអ្វីខុសក្នុងនយោបាយ ឬ ទើបបានក្រុមស្តាំផុតនិយមបែប«ណាស៊ី»លេចឡើងនៅប្រទេសបារាំងបាន?

ដំបូងពួកស្តាំផុតនិយមបានផុសឡើងខ្លាំងនៅអាមេរិកជាមួយក្រុម ខេខេខេ ឬ នៅអាល្លឺម៉ង់ជាមួយ ណាស៊ី, ក្រោយមកបន្ទាប់ពីរបបណាស៊ីស្លាប់ទៅជាមួយនឹង«ហ៊ីត្លែ»ក៏នៅសេសសល់គំនិត«អ្នកស្អប់ពូជសាសន៍ដ៏ទៃ ហើយមិនអាចទប់ចិត្តមិនបំផ្លាញចោលមិនបាន»នៅឡើយ ហើយគំនិតនោះនៅជិតជាប់នឹងអ្នកដែលមាននយោបានគ្រប់គ្រងផ្តាច់ការនិយម ក៏នៅរីករាយសុះសាយរហូតមកដល់ថ្ងៃនេះ ជាមួយក្រុមអតីត ណាស៊ី ឬក្រុម ខេខេខេ ជាដើម, ហើយមានបារាំងខ្លះយល់ថាក្រុមទាំងនោះធ្វើត្រូវ។

បារាំងជាច្រើន នៅពេលបោះឆ្នោតដោយខឹងនឹងរដ្ឋាភិបាលបារាំងលោក ម៉ាក្រុង ដែលមាននយោបាយរឹតត្បិត ឬមិនមានចិត្តទូលាយ ក៏បោះ«ឆ្នោតកំហឹង»នោះទៅឲ្យក្រុមផ្តាច់ការនិយមមាន ក្រុម ម៉ារីន ឡឺប៉ិន ឬក៏ក្រុមកុម្មុយនិស្តជាដើម ដែលធ្វើឲ្យលទ្ធផលឆ្នោតចេញជាយ៉ាងគ្រោះថ្នាក់ជាទីបំផុតនេះ ដែលជាការខូចប្រយោជន៍ដល់ ជនជាតិឯទៀត ដែលបានចូលមករស់នៅកសាងប្រទេសបារាំងជាមួយគ្នា ដល់ប្រទេសបារាំងទាំងមូល នឹងដល់សហភាពអឺរ៉ុបផង ៕



តមកពីទំព័រទី ០១

## បោះឆ្នោតក្រុមប្រឹក្សាស្រុក-ក្រុង-ខណ្ឌ

រើស«ក្រុមប្រឹក្សាស្រុក,ខណ្ឌ,ខេត្តនឹងក្រុង» នៅកម្ពុជាបានប្រព្រឹត្តទៅនៅថ្ងៃទី២៦ឧសភា២០២៤សម្រាប់អាណត្តិ៥ឆ្នាំដោយការបោះឆ្នោតសមមាត្រនឹងមិនសាកល។ គណបក្សចំនួន៥ ចូលរួមប្រកួតប្រជែងគ្នា ដោយមានបេក្ខជនឈរឈ្មោះទាំងអស់ចំនួន២ម៉ឺននាក់៖ ១គណបក្សប្រជាជនកម្ពុជា ២គណបក្សឆន្ទៈខ្មែរ ៣ គណបក្សរាជានិយម ហ្វ៊ុនស៊ិនប៉ិច ៤ គណបក្សរួបរួមជាតិ នឹង ៥ គណបក្សកម្លាំងជាតិ ។ «ក្រុមប្រឹក្សាស្រុក»គឺជាការគ្រប់គ្រងតំបន់ដែលរួមប្រជុំដោយ«ឃុំ ភូមិ»មួយចំនួននៅតាមខេត្ត,«ក្រុមប្រឹក្សាខេត្ត»គឺជាការគ្រប់គ្រងតំបន់នៃស្រុករីឯ«ក្រុមប្រឹក្សាខណ្ឌ»គឺជាការគ្រប់គ្រងតំបន់ដែលរួមប្រជុំដោយ«សង្កាត់»មួយចំនួន នឹង«ទីប្រឹក្សាក្រុង ឬរាជធានី» ជាការគ្រប់គ្រងតំបន់នៃទីរួមខណ្ឌក្នុងក្រុង ឬក្នុងរាជធានី។

គណបក្សប្រឆាំងដ៏សំខាន់ជាងគេមួយគឺ គណបក្សភ្លើងទៀន មាននិន្នាការជាអតីតគណបក្សសង្គ្រោះជាតិ បន្តវេនពីលោក សមរង្ស៊ី បានត្រូវរារាំង ដោយឈរឈ្មោះបោះឆ្នោតមិនបានរដ្ឋាភិបាលចោទថាមិនមានឯកសារត្រឹមត្រូវសម្រាប់ចុះឈ្មោះឲ្យបានស្របច្បាប់,តែគណបក្សនេះបានទៅធ្វើសម្ព័ន្ធភាព ជ្រកក្រោមស្លាបនៃ គណបក្សឆន្ទៈខ្មែរ ដំណាងដោយលោកសុកហាចដែលជានិន្នាការនៃគណបក្សសង្គ្រោះជាតិដូចគ្នាមួយទៀតហើយក៏បានសហការគ្នាបង្ហាញបេក្ខជនរួម បានច្រើនស្រុកនឹងខណ្ឌនឹងគេដែរថ្វីត្បិតតែមានសេចក្តីរាយការថា មានការដាក់សម្ពាធលើបក្សប្រឆាំងមួយនេះពីសំណាក់រដ្ឋាភិបាល ជាច្រើនកន្លែងក៏ដោយ។

រីឯគណបក្សកម្លាំងជាតិវិញ ដំណាងដោយលោក រ៉ង ឈុន បានឈរឈ្មោះឃោសនាដោយខ្លួនឯង នឹង គណបក្សទ្រទ្រង់ជាតិកម្ពុជា ដំណាងដោយលោកប៉ុល ហំ ជាគណបក្សប្រឆាំងក្នុងសម្ព័ន្ធភាព១ផ្សេងទៀត តែពុំមានបង្ហាញបេក្ខភាពរបស់ខ្លួន នៅពេលនេះនឹងគេដែរនោះទេ។ នៅសល់ គណបក្សហ្វ៊ុនស៊ិនប៉ិច ដំណាងដោយទ្រង់ នរោត្តមចក្រាវុឌ្ឍ នឹង គណបក្សខ្មែររួបរួមជាតិដំណាងដោយឧត្តមសេនីយ ញឹក ប៊ុនឆៃ ក៏បានឈរឈ្មោះដាក់បេក្ខជនរបស់ខ្លួនតាមមណ្ឌល នឹងធ្វើការឃោសនាបានតាមលទ្ធភាព នឹងតាមសំហារនៃសេរីភាពដែលបើកចំហរបន្តិចបន្តួច ដោយលោកអតីតនាយករដ្ឋមន្ត្រីហ៊ុន សែន។




ផែនទី រាជធានី ខេត្ត, នឹងក្រុង នៃកម្ពុជា

រំលឹកថាៈ កាលពីឱកាសបោះឆ្នោតខណ្ឌនឹងស្រុក នាឆ្នាំ២០១៩ មានគណបក្ស៧ចូលរួមបោះឆ្នោត លទ្ធផលបានទៅគណបក្សប្រជាជនកម្ពុជាចំនួន៣៤៤៨អាសនៈ, គណបក្សហ្វ៊ុនស៊ិនប៉ិចបាន ៣៣អាសនៈ, នឹងគណបក្សខ្មែររួបរួមជាតិបាន ៣៨អាសនៈ។ចំណែកឯបរិយាកាសនៃការបោះឆ្នោត គិតចាប់តាំងពីឆ្នាំ១៩៩៧ (ឆ្នាំនៃរដ្ឋប្រហាររបស់គណបក្សប្រជាជនដណ្តើមយកអំណាចតែម្នាក់ឯង) មកវិញ បានត្រូវអ្នកសង្កេតការពីភពលោក និយាយថា«មិនមានភាពប្រក្រតីនឹងមិនស្មើភាព...»ហើយលទ្ធផលវិញបានទៅគណបក្សកាន់អំណាចស្ទើរតែទាំងអស់ គ្រប់ពេល។

សម្លេងអ្នកមកបោះឆ្នោត មកពីក្រុមប្រឹក្សាឃុំសង្កាត់មាន១១៦២២សម្លេង ជាសម្លេងរបស់ក្រុមប្រឹក្សាឃុំសង្កាត់ ដែលបានជាប់ឆ្នោតពី២ឆ្នាំមុនហើយដែលត្រូវចេញទៅបោះឆ្នោតនៅ២០៩មណ្ឌលរាយនៅពាសពេញកម្ពុជា, នៅមណ្ឌលនិមួយៗអ្នកទាំងនោះត្រូវបោះឆ្នោត២ដងគឺម្តងសម្រាប់«ក្រុមប្រឹក្សាស្រុកនឹងខណ្ឌ»ដែលមាន ៣៦៤១អាសនៈ នឹងម្តងទៀតសម្រាប់«ក្រុមប្រឹក្សាក្រុងនឹងខេត្ត»ដែលមាន ៥៥៩អាសនៈ។

នៅមុនពេលប្រការលទ្ធផលជាផ្លូវការដោយគ.ជ.ប.មិនខុសអីពីការគិតទុកជាមុនទេ គណបក្សប្រជាជនកម្ពុជា បានឈ្នះភ្លូកទឹកភ្លូកដី សាជាថ្មីម្តងទៀត ដោយប្រមូលបានឆ្នោត៨៦%ត្រូវនឹង៩៩៨៦សម្លេង រីឯបក្សប្រឆាំងនឹងគណបក្សផ្សេងទៀត ទទួលបានសម្លេងឆ្នោត១១% ស្មើនឹង១២៨៦សម្លេង ៕

# Cambodia Provincial and District Council Election

Europe, 01 June 2024

The District, Provincial and Municipal Councils” election in Cambodia took place on May 26, 2024, for a five-year term, with proportional and non-universal elections. Five parties competed with a total of 20,000 candidates: 1) Cambodian People's Party, 2) Khmer Will Party, 3) Royalist Party, FUNCINPEC, 4) the National Unity Party and 5) National Forces Party. The “District Council” is the management of the area, which is convened by some "communes" in the provinces, "Provincial Council" is the management of the area of the district, and "Khan Council" is the management of the meeting area. Some “Sangkats” and “municipal or capital councilors” oversee the area of the municipal town or city.

The main opposition party, Candlelight Party, which tends to be a former CNRP successor to Sam Rainsy, has been barred from running in the by-elections take refuge under the wing of the Khmer Will Party, represented by Mr. Sok Hach, another trend of the same CNRP and cooperated to show the common candidates in many districts and districts, despite reports that there is pressure on the opposition party from governments.

The National Forces Party, represented by Rang Chhun, ran for office on its own, and the Cambodian National Rescue Party, represented by Pol Horm, an opposition party in another coalition, did not present its candidacy at this time.

FUNCINPEC, represented by Norodom Chakravuth and the Khmer United National Party, represented by General Nhek Bun Chhay, also fielded their candidates in the constituencies and campaigned as much as possible in the spirit of a little more open freedom by former Prime Minister Hun Sen.

Recall the district council elections in 2019, there were 7 parties participating in the election, the results went to the Cambodian People's Party 3448 seats, FUNCINPEC 33 seats and the Khmer United National Party 38 seats. As for the election environment since 1997 (the year of the coup d'état of the CPP alone), observers from around the world have said that "irregularities and inequities ... and the result goes to the ruling party almost all the time.

Voter turnout from the Commune / Sangkat Council was 11,622, the voice of the Commune / Sangkat Council, which was elected two years ago and went to the polls in 209 constituencies across Cambodia, in each constituency. Two elections were held once for the "District and Khan Council" with 3,641 seats and again for the "Municipal and Provincial Councils" with 559 seats.

Prior to the official results by the NEC, unexpectedly, the CPP won another landslide victory with 86% of 9,986 votes, while the opposition and other parties received 11% of 1286 votes.

តមកពីទំព័រទី ០៨

# ព្រឹទ្ធសមាជិកសភា ប្រោន(Brown)

ថា "មានភ័ស្តុតាងច្រើនក្រៃលែងដែលបង្ហាញថា វៀតណាមមិនបំពេញតាមលក្ខខណ្ឌច្បាប់ដែលបង្កើតឡើងដោយសភា ដើម្បីទទួលបានឋានៈសេដ្ឋកិច្ចទីផ្សារ។ យើងមានការព្រួយបារម្ភជាពិសេសចំពោះរបាយការណ៍ដែលក្រសួងពាណិជ្ជកម្មបានសន្យាជាមួយរដ្ឋាភិបាលវៀតណាមថា ការត្រួតពិនិត្យរបស់ទីភ្នាក់ងាររបស់អ្នកនឹងនាំឱ្យមានការប្តេជ្ញាចិត្តដ៏អំណោយផលធ្វើឲ្យប៉ះពាល់ដល់ឧស្សាហកម្មនិងកម្មករសហរដ្ឋអាមេរិក។ សមាជិកព្រឹទ្ធសភាបានសរសេរនៅក្នុងលិខិតរបស់ពួកគេថា យើងជំរុញឱ្យក្រសួងពាណិជ្ជកម្មពិនិត្យមើលភស្តុតាងពេញលេញ នៅពេលខ្លួនធ្វើការពិនិត្យឡើងវិញ និងពិចារណាពីផលប៉ះពាល់លើការងារ និងអ្នកផលិតរបស់អាមេរិកក្នុងការសម្រេចចុងក្រោយរបស់ខ្លួន"។

លិខិតរបស់ព្រឹទ្ធសភាបន្តថា "ការផ្តល់ឋានៈអនុគ្រោះផ្នែកសេដ្ឋកិច្ចទីផ្សារវៀតណាមមុនពេលវៀតណាមដោះស្រាយអាកប្បកិរិយាមិនទីផ្សារច្បាស់លាស់របស់ខ្លួន និងកង្វះខាតធ្ងន់ធ្ងរនៅក្នុងច្បាប់ការងារនឹងធ្វើឱ្យខូចទ្រង់ទ្រាយពាណិជ្ជកម្មដែលកំពុងមាន បំផ្លាញមូលដ្ឋានផលិតកម្មរបស់សហរដ្ឋអាមេរិកគំរាមកំហែងកម្មករ និងឧស្សាហកម្មអាមេរិក និងពង្រឹងតួនាទីរបស់វៀតណាមជាលំហូរសម្រាប់ទំនិញដែលផលិតនៅក្នុងប្រទេសចិន ដែលមានពលកម្មដោយបង្ខំ។ យើងជំរុញឱ្យអ្នក និងទីភ្នាក់ងាររបស់អ្នកពិចារណាឱ្យបានហ្មត់ចត់អំពីលក្ខខណ្ឌសេដ្ឋកិច្ច និងការងារនៅក្នុងប្រទេសវៀតណាម នៅពេលអ្នកធ្វើការត្រួតពិនិត្យស្ថានភាពសេដ្ឋកិច្ចទីផ្សាររបស់វៀតណាម ហើយជឿថាភស្តុតាងចង្អុលទៅការសន្និដ្ឋានមួយដែលថា៖ វៀតណាមមិនបំពេញតាមលក្ខខណ្ឌតម្រូវដើម្បីទទួលបានស្ថានភាពអនុគ្រោះផ្នែកសេដ្ឋកិច្ចទីផ្សារក្រោមពាណិជ្ជកម្មច្បាប់សហរដ្ឋអាមេរិកទេ។ បើមិនដូច្នេះទេ នឹងធ្វើឱ្យច្បាប់អនុវត្តពាណិជ្ជកម្មរបស់យើងចុះខ្សោយ និងធ្វើឱ្យប៉ះពាល់ដល់ជីវភាពរស់នៅរបស់កម្មករអាមេរិក"។

តទៅទំព័រទី១៥

# BROWN WARNS ADMINISTRATION THAT GRANTING VIETNAM MARKET ECONOMY

From Page 08

believe the evidence points to one conclusion: Vietnam does not meet the requirements to receive market economy status under U.S. trade law. To find otherwise would weaken our trade enforcement laws and jeopardize the livelihoods of American workers," they continued.

In October 2023, the Commerce Department announced the initiation of a changed circumstances review (CCR) of Vietnam's nonmarket economy status. The Tariff Act of 1930 established a six-factor test to determine whether or not a country qualifies as a nonmarket economy, and the lawmakers note that the reality of Vietnam's economy—including evidence collected by the U.S. government itself—shows Vietnam does not meet any of the first five factors.

The sixth factor the Commerce Department is required to consider is a catch-all, giving it the flexibility to consider additional factors it deems appropriate. The lawmakers urged the Commerce Department, as part of its evaluation of Vietnam's ability to meet the sixth factor, to take into account Vietnam's close economic relationship with China, especially as China and Vietnam actively seek to further deepen their trade ties. Vietnam's manufacturing sector relies heavily on inputs from China, making it "vulnerable to forced labor risks in supply chains."

Brown has long been a leader in strengthening trade enforcement, specifically to target how China uses Southeast Asian countries like Vietnam to subvert trade rules meant to level the playing field for Ohio workers. His Leveling the Playing Field 2.0 Act would establish new tools to improve the effectiveness of the U.S. trade remedy system in responding to "country hopping" by China. In August 2023, the Commerce Department issued a final determination uncovering that Chinese solar panel producers – operating in Southeast Asia, including in Vietnam – are circumventing U.S. trade law meant to protect American businesses and workers by routing their products through

Please see /15









តមកពីទំព័រទី ១៤

# ព្រឹទ្ធសមាជិកសភា ប្រោន(Brown)

នៅខែតុលា ឆ្នាំ ២០២៣ ក្រសួងពាណិជ្ជកម្មបានប្រកាសចាប់ផ្តើមការពិនិត្យឡើងវិញនូវកាលៈទេសៈផ្លាស់ប្តូរ ហៅកាត់ថា (CCR) នៃស្ថានភាពសេដ្ឋកិច្ចមិនទីផ្សាររបស់វៀតណាម។ ច្បាប់ពន្ធដារនៃឆ្នាំ ១៩៣០ បានធ្វើតេស្តកត្តាប្រាំមួយ ដើម្បីកំណត់ថាតើប្រទេសមួយមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាសេដ្ឋកិច្ចមិនទីផ្សារ ឬអត់ ហើយសមាជិកសភាបានកត់សម្គាល់ថាការពិតនៃសេដ្ឋកិច្ចរបស់វៀតណាម រួមទាំងភស្តុតាងដែលប្រមូលបានដោយរដ្ឋាភិបាលសហរដ្ឋអាមេរិកខ្លួនឯង បង្ហាញថាវៀតណាមមិនឆ្លើយតបនឹងអ្វីទាំងអស់ទៅនឹងកត្តាប្រាំដំបូង។

កត្តាទីប្រាំមួយ ដែលក្រសួងពាណិជ្ជកម្មតម្រូវឱ្យពិចារណា គឺការចាប់យកទាំងអស់ ដែលផ្តល់ឱ្យនូវភាពបត់បែនក្នុងការពិចារណាលើកត្តាបន្ថែមដែលក្រសួងយល់ថាសមស្រប។សមាជិកសភាបានជំរុញឱ្យក្រសួងពាណិជ្ជកម្ម ដែលជាផ្នែកមួយនៃការវាយតម្លៃសមត្ថភាពរបស់វៀតណាមក្នុងការបំពេញកត្តាទីប្រាំមួយ ដើម្បីគិតគូរពីទំនាក់ទំនងសេដ្ឋកិច្ចជិតស្និទ្ធរបស់វៀតណាមជាមួយចិន ជាពិសេសនៅពេលដែលប្រទេសចិន និងវៀតណាមកំពុងស្វែងរកយ៉ាងសកម្មនូវទំនាក់ទំនងពាណិជ្ជកម្មរបស់ពួកគេឱ្យកាន់តែស៊ីជម្រៅថែមទៀត។ វិស័យផលិតកម្មរបស់វៀតណាមពឹងផ្អែកយ៉ាងខ្លាំងលើធាតុចូលពីប្រទេសចិន ដែលធ្វើឱ្យវា "ងាយរងគ្រោះនឹងមានហានិភ័យការងារដោយបង្ខំនៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់"។

ព្រឹទ្ធសភា Brown គឺជាអ្នកដឹកនាំយូរមកហើយក្នុងការពង្រឹងការអនុវត្តពាណិជ្ជកម្ម ជាពិសេសដើម្បីកំណត់ពីរបៀបដែលប្រទេសចិនប្រើប្រាស់បណ្តាប្រទេសអាស៊ីអាគ្នេយ៍ដូចជាវៀតណាម ដើម្បីបង្វែរច្បាប់ពាណិជ្ជកម្មដែលមានបំណងកម្រិតទីផ្សារ ធ្វើឲ្យប៉ះពាល់ដល់កម្មករនៅរដ្ឋ Ohio។ ច្បាប់ស្តីពីការកម្រិតទីផ្សារ ២.០ (Leveling the Playing Field 2.0) របស់គាត់នឹងបង្កើតឧបករណ៍ថ្មីដើម្បីបង្កើនប្រសិទ្ធភាពនៃប្រព័ន្ធដោះស្រាយពាណិជ្ជកម្ម របស់សហរដ្ឋអាមេរិកឆ្លើយតបទៅនឹង "ការរំលងលោតផ្លោះប្រទេស"ដោយប្រទេសចិន។ នៅខែសីហា ឆ្នាំ ២០២៣ក្រសួងពាណិជ្ជកម្មបានចេញការប្តេជ្ញាចិត្តចុងក្រោយដែលបង្ហាញថា អ្នកផលិតបន្ទះសូឡារបស់ចិន ដែលប្រតិបត្តិការនៅអាស៊ីអាគ្នេយ៍ រួមទាំងនៅវៀតណាម កំពុងគេចចេញពីច្បាប់ពាណិជ្ជកម្មរបស់សហរដ្ឋអាមេរិក ដែលមានបំណងការពារអាជីវកម្ម និងកម្មករអាមេរិកដោយការបញ្ជូនផលិតផលរបស់ពួកគេតាមរយៈប្រទេសទាំងនេះ។ ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ លោក Brown បានជំរុញឱ្យការពារកម្មកររដ្ឋ Ohio ពីការអនុវត្តពាណិជ្ជកម្មមិនយុត្តិធម៌ក្នុងប្រទេស វៀតណាមក្នុងឧស្សាហកម្មចាប់ពីសំបកកង់រហូតដល់ពូក។



U.S Senator Sherrod Brown, D-Ohio

ព្រឹទ្ធសមាជិក Brown បានចូលរួមនៅក្នុងការផ្ញើសំបុត្រដោយព្រឹទ្ធ Sens. Elizabeth Warren (D-MA), Tammy Baldwin (D-WI.), Bob Casey (D-PA), Debbie Stabenow (D-MI), Bernie Sanders (I-VT ), John Fetterman (D-PA), និង Tina Smith (D-MN) ។

តទៅលេខក្រោយ

# BROWN WARNS ADMINISTRATION THAT GRANTING VIETNAM MARKET ECONOMY

From Page 14

these countries. In recent years, Brown has pushed to protect Ohio workers from unfair trade practices in Vietnam in industries from tires to mattresses.

Senator Brown was joined in sending the letter by Sens. Elizabeth Warren (D-MA), Tammy Baldwin (D-WI.), Bob Casey (D-PA), Debbie Stabenow (D-MI), Bernie Sanders (I-VT), John Fetterman (D-PA), and Tina Smith (D-MN).

Please see Next Issue

# Analysis: Can Palestine become a full member of the United Nations?

From Page 10

cannot grant full membership.

Today, Palestine has the name as an observer state, not a member, a status granted by the United Nations General Assembly in 2012.

The Security Council is one of the top five bodies of the United Nations. It has 15 members, including five permanent members, which are responsible for ensuring international peace and security and recommending new members to the General Assembly. Its powers include the establishment of peacekeeping operations, international sanctions, and authorization of military action under the auspices of the United Nations, known as the "Peacekeepers."

The Security Council is the only body of the United Nations that has the authority to issue decisions on which countries to enforce. However, if any decision can be made, it can only be done by a unanimous vote without any objection from any permanent member. The five permanent members are the United States, Britain, France, Russia and China. "Resolutions" adopted by the United Nations Security Council.

Palestine grapes another opportunity for full UN membership amid full-scale war in Gaza.

Efforts to apply for full Palestinian UN membership come at a time when the war between Israel and Hamas-Palestine in the Gaza Strip has dragged on for more than seven months. In the UN General Assembly elections, both Israel and the United States voted against. Israel, meanwhile, is still considered a life and dead ally by the United States for its geopolitical and military interests in the Middle East.

The war in the Gaza is an Israeli war of revenge because Hamas took refuge in the Gaza, which fired about 500 rockets into Israeli territory on October 7, 2023. Hamas acts like this have led the United States to commit acts of terrorism that have killed more than 1,200 Israelis.

However, the Israeli-Gaza war in Gaza has been almost completely over, but Israel is planning to root out and dismantle the Hamas stronghold, which Israel calls a "terrorist force" under the banner of territorial defense of Palestine.

As Israel has almost completely dismantled Hamas, Palestinian Mahmoud Rida Abbas has stated that Hamas is not part of the Palestinian National Armed Forces. The Palestinian president apparently wants to tell the world that the group's presence in Gaza is illegal. But the group is said to have received arms supplies and Iranian-backed funding.

Thus, the United States decided to vote against the majority vote of the countries that support the application for membership of the Palestinian Territories in the election of the United Nations General Assembly on May 10.

However, the fate of Palestine, which wants to become a member of the United Nations, will have to go through the will of the United States at the UN Security Council meeting again.

Can Palestine become a member of the United Nations?

In the next few days, it is expected that the UN Security Council will convene again at the request of any member of the Security Council, following the recommendations of the election results of the case. The Palestinian Authority received overwhelming support from 143 of the 193 UN member states on Friday. However, the fate of Palestine is, of course, entirely dependent on the United States.

In principle, the elections of the members of the UN Security Council are of three types, as in the case of the United Nations General Assembly: there are pro-votes, vote of abstention vote and opposition vote.

In these three types of votes, the weighted votes consist of a vote for and a vote against or objection. The abstention vote has no weight. Abstentions are considered as an expression of their willingness to prove their presence at the meeting, and they do not want to be involved. That means they want to stand in the middle.

In the elections at the UN General

Please see /19

តមកពីទំព័រទី ០៥

# ពេលដែលកងកម្លាំងអ៊ុយក្រែនផ្តើម

ពេលបន្តិចមែនតែនៅរដូវរងាកន្លងទៅនេះ កងទ័ពលោក ជេឡិនស្គី បានបង្ហាញថា ពួកគេនៅតែតស៊ូការពារទឹកដីរបស់ខ្លួនឲ្យបានស្វិតស្វាញ ហើយជាពិសេស បង្ហាញប្រទេសទាំងអស់នៅអឺរ៉ុបថាអ៊ុយក្រែនក៏កំពុងតែការពារជំនួសឲ្យទាំងអស់គ្នាពីការប៉ុនប៉ងវាតទី របស់រុស្ស៊ីមកលើទឹកដីអឺរ៉ុបផងដែរ។ ឃើញឧទាហរណ៍បែបនេះ ហើយ ប្រទេសជាច្រើន ដែលនៅជាប់នឹងព្រំដែនប្រទេសរុស្ស៊ី មានការភិតភ័យនឹងមហិច្ឆិតារបស់មហាអំណាចមួយនេះក៏បានត្រៀមខ្លួនចូល«អូតង់»យ៉ាងប្រញាប់ប្រញាល់ដែរ ដូចជាប្រទេសម៉ុលដាវី ជាដើម។

ចំណែកឯភាគីរុស្ស៊ីរបស់ពូទីនវិញហាក់ដូចជាមិនមានការព្រួយបារម្ភណាមួយទេ បើយោងតាមព័ត៌មានក្នុងប្រទេសរុស្ស៊ីប៉ុន្តែតាមសេចក្តីរាយការតាមសារព័ត៌មានសេរីធំៗវិញបង្ហាញឲ្យឃើញថារុស្ស៊ីមានឱនភាពថវិកាយ៉ាងសន្ធឹកសន្ធាប់ ដោយសហគ្រាស នឹងឧស្សាហកម្មដោយបរទេស បានដកខ្លួនចេញ, អឺរ៉ុបក៏ឈប់លែងទិញប្រេងឬឧស្ម័នពីរុស្ស៊ីតាំងតែពីជាងមួយឆ្នាំមកហើយនៅសល់តែទំនិញជាថាមពលខ្លះៗលក់ឲ្យទៅចិន បានក្នុងតម្លៃយ៉ាងថោក ហើយឥឡូវទៅយកអាវុធ នឹងគ្រឿងចម្បាំងពីកូរ៉េខាងជើង យកជូនពីអ៊ីរ៉ង់ ចំណែកឯនយោបាយសេដ្ឋកិច្ចចិនវិញក៏បានលបផ្តល់សម្ភារៈអេឡិកត្រូនិកឲ្យទៅរុស្ស៊ីខ្លះដែរ ដោយមិនចង់ឲ្យមានបញ្ហាពាណិជ្ជកម្មជាមួយ អាមេរិកាំងនឹងអឺរ៉ុប ។

នៅខែឧសភា២០២៤នេះ ទ័ពរុស្ស៊ីប្តើមទទួលការវាយបកដ៏ខ្លាំងខ្លាពីសំណាក់ទ័ពអ៊ុយក្រែង, បើតាមសេចក្តីរាយការសេនាធិការអង់គ្លេសបាននិយាយថា គ្រាន់តែពីថ្ងៃទី២ ទៅ៣មិថុនានេះ ទាហ៊ានរុស្ស៊ីបានខូចខាត១២៧០នាក់ គឺជាការខូចខាតដ៏ច្រើនបំផុតរបស់រុស្ស៊ី ចាប់តាំងពីប្តើមសង្គ្រាមមក, ហើយនៅខែឧសភាកន្លងទៅការខូចខាតមានចំនួន១២០០នាក់ក្នុងមួយថ្ងៃ បើគិតចាប់តាំងពីពេលប្តើមសង្គ្រាមមក រុស្ស៊ីបានខូចខាតកងទ័ពជាង៥០ម៉ឺននាក់ទៅហើយនេះបើតាមចំនួនប្រភពអ៊ុយក្រែន, ខាងអង់គ្លេសពិពត៌នាថា យោធាខាងរុស្ស៊ីមានការហាត់ហ្វឹកហ្វឺនតិចតួច ដែលយកមកឲ្យច្បាំងនៅសមរភូមិធំ។ ចំណែកកខាងសម្ភារៈចម្បាំងវិញរុស្ស៊ីខូចខាតរថក្រោះចំនួន ៣១៨គ្រឿង រថពាសដែកចំនួន៥៥០គ្រឿង យន្តហោះប្រដេញចំនួន១៦គ្រឿង ឧទ្ធម្ភាគចក្រចំនួន៣៥គ្រឿង នាវាសមុទ្រ២គ្រឿង។

ចំណែកឯខាងទ័ពអ៊ុយក្រែងវិញការខូចខាតពិបាកនឹងយកព័ត៌មានចេញមកបាន ដោយសារតែការលាក់ការខូចខាតមនុស្ស ជារឿងសម្ងាត់ តែក៏គេអាចដឹងថានៅសមរភូមិមានការខូចខាតរថគ្រោះចំនួន៧៩គ្រឿង យន្តហោះប្រដេញចំនួន១២គ្រឿង រថពាសដែកចំនួនជិត២០០គ្រឿង នាវាចំនួន១៣គ្រឿង។ ការខូចខាតមនុស្សខាងកងទ័ពលោក ជេឡិនស្គីអាចសន្និដ្ឋានថាមានតិចតួចដោយសារអ៊ុយក្រែន បានប្រកាន់យកការប្រយុទ្ធគំរូទ័ពព្រៃ តែប្រើបច្ចេកទេសនឹងអាវុធទំនើប មិនច្បាំងប្រឈមមុខសត្រូវទេ ដូច្នេះគេប៉ាន់ស្មានបានថា ការខូចខាតមនុស្សមាន៥ ទៅ១០ដង តិចជាងការខូចខាតរបស់រុស្ស៊ី ។ បន្ថែមពីនោះកងទ័ពអ៊ុយក្រែន មានមនុស្សស្ម័គ្រចិត្តចូលប្រយុទ្ធ មកពីអឺរ៉ុប នឹងប្រទេសផ្សេងទៀតជាច្រើននាក់ ដែលមិនបានធ្វើឲ្យអ៊ុយក្រែនរអ៊ូថា«ខ្វះកងទ័ព»នោះទេ។

ថ្ងៃទី៧ លោកជេឡិនស្គី មកដល់ប្រទេសបារាំង ក្នុងឱកាសបុណ្យរំលឹកខួប«ទម្លាក់ទ័ពនៅន័រម៉ង់ឌី» លោកនឹងជួបប្រធានាធិបតី ម៉ាក្រុង ជួបប្រធានាធិបតីជោ បាយដិន ដែលមកពីធីបុណ្យ៩មិថុនា នឹងទៅជួបប្រទេសអឺរ៉ុបជាច្រើនទៀត ដើម្បីយុទ្ធវិធីថ្មី ក្នុងការបញ្ចប់សង្គ្រាមនៅអ៊ុយក្រែន ប៉ុន្តែគេដឹងថា ជេឡិនស្គី ចង់បញ្ចប់សង្គ្រាមដោយមិនត្រូវឲ្យបាត់បង់ គ្រីម៉េ ទេ។












## PUBLIC NOTICE

Lowell Regional Transit Authority (LRTA)

Disadvantaged Business Enterprise (DBE) Goals

For Federal Transit Administration (FTA) Assisted Activities

Federal Fiscal Years 2025-2027

In accordance with FTA Regulations, LRTA has established goals for participation by certified Disadvantaged Business Enterprise (DBE) firms of the Authority's federally assisted transit projects and procurements anticipated for Federal Fiscal Years 2025-2027

LRTA recommends an overall DBE goal of 4.61% for Federal Fiscal Years 2025-2027. A description and information on the methodology used to establish the LRTA's FFY 2025-2027 DBE goal is available at www.lrta.com and will be available for inspection for thirty (30) days following this publication at the LRTA Administrative Office, 115 Thorndike Street, 3rd Floor, Lowell MA 01852 during normal business working hours 8:00 AM – 4:00 PM.

Comments regarding the goal and the methodology used for developing the same will be accepted for Forty-five (45) days from June 17, 2024. Comments may be emailed to justin.howard@lrta.com or addressed to the LRTA at the above address.

Comments may also be directed to the FTA Civil Rights Officer at Federal Transit Administration, 55 Broadway, Suite 920, Cambridge, MA 02142.

## សេចក្តីជូនដំណឹងជាសាធារណៈ

អាជ្ញាធរដឹកជញ្ជូនឆ្លងកាត់តំបន់ ឡូវែល (LRTA)

គោលដៅសហគ្រាសអាជីវកម្មដែលជួបវិបត្តិ (DBE)

សម្រាប់សកម្មភាពឆ្លងកាត់ដែលត្រូវការជំនួយរដ្ឋបាលសហព័ន្ធ (FTA)

ឆ្នាំសារពើពន្ធសហព័ន្ធ ២០២៥-២០២៧

ដោយអនុលោមតាមបទប្បញ្ញត្តិ ស្តីពីសកម្មភាពឆ្លងកាត់ដែលត្រូវការជំនួយរដ្ឋបាលសហព័ន្ធ (FTA) អាជ្ញាធរដឹកជញ្ជូនឆ្លងកាត់តំបន់ឡូវែល (LRTA) បានបង្កើតគោលដៅសម្រាប់ការចូលរួមពីក្រុមហ៊ុនសហគ្រាសអាជីវកម្មដែលជួបវិបត្តិ (DBE) គម្រោងឆ្លងកាត់ដែលត្រូវការជំនួយរដ្ឋបាលសហព័ន្ធ និងលទ្ធកម្មរបស់អាជ្ញាធរ គ្រោងសម្រាប់ឆ្នាំសារពើពន្ធសហព័ន្ធ ២០២៥-២០២៧ ។

LRTA ផ្តល់អនុសាសន៍សម្រាប់គោលដៅ DBE ៤.៦១% សម្រាប់ឆ្នាំសារពើពន្ធសហព័ន្ធ ២០២៥-២០២៧ ។ ការពិពណ៌នា និងព័ត៌មានអំពីវិធីសាស្ត្រដែលត្រូវប្រើដើម្បីបង្កើតគោលដៅសម្រាប់ឆ្នាំសារពើពន្ធសហព័ន្ធ ២០២៥-២០២៧ របស់ LRTA មាននៅលើគេហទំព័រ www.lrta.com ហើយនឹងមានសម្រាប់ការត្រួតពិនិត្យរយៈពេល ៣០ ថ្ងៃបន្ទាប់ពីការបោះពុម្ពផ្សាយនេះនៅការិយាល័យរដ្ឋបាល LRTA ផ្លូវ ១១៥ Thorndike ជាន់ទី៣3 ទីក្រុងឡូវែល MA 01852 ពេលម៉ោងធ្វើការ ធម្មតា ៨:00 ព្រឹក ដល់ ៤:00 ល្ងាច។

មតិយោបល់ទាក់ទងនឹងគោលដៅ និងវិធីសាស្ត្រដែលត្រូវប្រើសម្រាប់ការអភិវឌ្ឍន៍ដូចគ្នា នឹងត្រូវបានទទួលយកសម្រាប់រយៈពេល ៤៥ ថ្ងៃចាប់ពីថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ ២០២៤។ មតិយោបល់អាចត្រូវបានផ្ញើតាមអ៊ីមែលទៅកាន់ justin.howard@lrta.com ឬផ្ញើទៅកាន់ LRTA តាមអាសយដ្ឋានខាងលើ។

មតិយោបល់ក៏អាចត្រូវបានបញ្ជូនទៅមន្ត្រីសិទ្ធិស៊ីវិល FTA នៅរដ្ឋបាលដឹកជញ្ជូនឆ្លងកាត់ តាមអាសយដ្ឋាន 55 Broadway, Suite 920, Cambridge, MA 02142។

តមកពីទំព័រទី ០៣

## ចាប់ផ្តើមកាត់ក្តីសកម្មជនមាតាធម្មជាតិ

ចូលតុលាការទេ។ លោក អាឡិចហ្សាន់ដ្រូ ហ្គន់ហ្សាឡេស ដាវីដសុន ដែលជាស្ថាបនិកដំបូងរបស់ក្រុមនេះ ត្រូវបាននិរទេសចេញពីប្រទេសកម្ពុជាក្នុងឆ្នាំ ២០១៥ ហើយនៅតែត្រូវបានហាមឃាត់មិនឱ្យចូលប្រទេស។ ៣ នាក់ទៀតគឺ មិញ ពិសិដ្ឋ វ៉ៃ រស្មី និងប៉ុក ខូយ ត្រូវបានចោទប្រកាន់ពីបទរៀបចំផែនការ ហើយមិនចូលខ្លួនទៅតុលាការ។

បើតាមប្រភពពីក្នុងបន្ទប់សវនាការបានឱ្យដឹងថា ការចាប់ផ្តើមសវនាការនេះ មានតែលោក លាង ហ៊ី ឈរឲ្យសួរនាំប៉ុណ្ណោះ បន្ទាប់មកតុលាការបានលើកពេលទទួលទានអាហារថ្ងៃត្រង់នៅម៉ោង ១១ និង៣០នាទីព្រឹក អង្គជំនុំជម្រះលើកពេលសវនាការពេញមួយថ្ងៃ ទៅថ្ងៃទី ៥ ខែមិថុនា។

ការកាត់ក្តីរបស់អង្គការមាតាធម្មជាតិកម្ពុជា ត្រូវបានពន្យារពេលម្តងហើយម្តងទៀត ហើយមានឈុតឆាករំជួលចិត្តនៅខាងក្រៅតុលាការ ខណៈដែលសកម្មជនទាំងប្រាំនាក់ដែលចូលរួមនោះ បានត្រៀមខ្លួនសម្រាប់ការវិលត្រឡប់ទៅកាន់ពន្ធនាគារវិញ។ ថន រដ្ឋា បីកូនតូចរហូតដល់ពេលចូលតុលាការ។

សកម្មជនជើងចាស់ អ៊ុច ពេជ្រសំណាង ឱប ភួន កែវរស្មី នៃអង្គការមាតាធម្មជាតិកម្ពុជា មុននឹងសកម្មជនបរិស្ថានឡើងសវនាការ។រូបភាពដោយ Gerald Flynn / Mongabay ។

នៅខាងក្រៅតុលាការមុនការកាត់ក្តីចាប់ផ្តើម ឡុង គន្ធា ដែលប្រឈមនឹងការជាប់ពន្ធនាគាររហូតដល់ ១០ ឆ្នាំ បានតវ៉ាចំពោះភាពគ្មានកំហុសរបស់ក្រុមសកម្មជនបរិស្ថាន។

អ្នកស្រីបានថ្លែងថា៖ "យើងជាប្រជាជនស្លូតត្រង់ ហើយយើងធ្វើការដើម្បីការពារផលប្រយោជន៍ជាតិ។" "ប្រសិនបើថ្ងៃនេះ តុលាការសម្រេចចោទប្រកាន់យើង ហើយចាប់យើងដាក់គុកម្តងទៀត យើងនៅតែអរគុណអ្នកទាំងអស់ដែលផ្តល់យុត្តិធម៌ដល់យើង ព្រោះតុលាការមិនដែលផ្តល់យុត្តិធម៌ដល់យើងទេ"។

ការចោទប្រកាន់ពីការរៀបចំផែនការចាប់តាំងពីឆ្នាំ ២០១២ ដល់ឆ្នាំ ២០២១ និងគ្របដណ្តប់លើសកម្មភាពរបស់អង្គការមាតាធម្មជាតិកម្ពុជា។ សកម្មជន៦នាក់ និង ៥ នាក់ដែលមានវត្តមាននៅតុលាការកាលពីថ្ងៃទី ២៩ ឧសភា បានជាប់ឃុំរួចហើយដោយសារតែសកម្មភាពរបស់ពួកគេ ប៉ុន្តែត្រូវបានដោះលែងឱ្យនៅក្រៅឃុំនៅថ្ងៃទី ១២ ខែវិច្ឆិកា ឆ្នាំ ២០២១។

យ៉ាងណាមិញ ការចោទប្រកាន់មិនត្រូវបានទម្លាក់ចោលឡើយ ហើយលក្ខខណ្ឌនៃការនៅក្រៅឃុំរបស់ពួកគេបានទាមទារឱ្យពួកគេបញ្ឈប់រាល់សកម្មភាពទាំងអស់។

អ្នកគាំទ្របានប្រមូលផ្តុំគ្នាដើម្បីជំរាបលា ឡុង គន្ធា និងសកម្មជនអង្គការមាតាធម្មជាតិកម្ពុជា ផ្សេងទៀត មុនពេលការកាត់ក្តីអ្នកបរិស្ថានបានចាប់ផ្តើមនៅថ្ងៃទី ២៩ ខែឧសភា ឆ្នាំ ២០២៤។ រូបភាពដោយ៖ Gerald Flynn / Mongabay ។

គន្ធា មានគម្រោងធ្វើបាតុកម្មស្ត្រីតែម្នាក់ឯង ប្រឆាំងនឹងការបន្តចាក់ដីចូលលុបបឹងក្នុងរាជធានីភ្នំពេញ ការបណ្តេញចេញនិងការកើនឡើងហានិភ័យទឹកជំនន់នៅក្នុងទីក្រុង។ ប៉ុន្តែការហែក្បួនរបស់នាងមិនដែលបានកើតឡើងទេ។ នាងត្រូវបានគេចាប់ដាក់ឡានប៉ូលិសមុនពេលនាងអាចចាប់ផ្តើម។

គន្ធា ថុនរដ្ឋា និងកែវរស្មី ទាំងអស់គ្នាត្រូវបានចាប់ខ្លួនកាលពីថ្ងៃទី៣ ខែកញ្ញា ឆ្នាំ ២០២០ ហើយត្រូវបានឃុំខ្លួនបណ្តោះអាសន្នរហូតដល់ថ្ងៃទី៥ខែឧសភា ឆ្នាំ ២០២១ ពួកគេត្រូវបានកាត់ទោសឱ្យជាប់ពន្ធនាគារម្នាក់ៗ ១៨ ខែ។ គន្ធា និង កែវរស្មី ត្រូវបានឃុំខ្លួននៅពន្ធនាគារស្ត្រីក្នុងរាជធានីភ្នំពេញមុនពេលដោះលែងឱ្យនៅក្រៅឃុំក្នុងខែវិច្ឆិកា ឆ្នាំ២០២១។

នាង គន្ធា បានមានប្រសាសន៍មុនពេលចូលទៅកាន់តុលាការថា៖ "យើងសង្ឃឹមថា អ្នកទាំងអស់គ្នានឹងបន្តធ្វើការដើម្បីបុព្វហេតុការពារធនធានធម្មជាតិនៅកម្ពុជា" ។

លោក លី ច័ន្ទតារាវុធ អតីតនិស្សិតច្បាប់ ក្លាយជាសកម្មជន មានប្រសាសន៍ថា លោកគ្មានការសោកស្តាយចំពោះសកម្មភាពរបស់លោកទេ ហើយថា គាត់ធ្វើដើម្បីប្រជាជនកម្ពុជា។

"យើងចង់ឃើញប្រជាជនយើងរស់នៅដោយសេចក្តីថ្លៃថ្នូរ។ យើងចង់

តទៅទំព័រទី២០

## Trial begins for Mother Nature Cambodia activists on conspiracy charge

From Page 03

woman protest against the continued infilling of Phnom Penh's lakes, the resultant evictions and increased flood risk posed to the city. But her march never happened. She was bundled into a police car before she could begin.



Supporters gathered to bid Long Kunthea and other Mother Nature Cambodia activists farewell before the environmentalists' trial began on May 29, 2024. Image by Gerald Flynn / Mongabay.

Kunthea, Thun Ratha and Keoreaksmey were all arrested on Sept. 3, 2020, and held in pretrial detention until May 5, 2021, when they were sentenced to 18 months each in prison. Kunthea and Keoreaksmey were confined to a women's prison in Phnom Penh before they were released on bail in November 2021.

"We hope you all stay strong and continue to work for the cause of protecting natural resources in Cambodia," Kunthea said before entering the court.

Ly Chandaravuth, a former law student turned activist, said he had no regrets for his activism and that it was done for the people of Cambodia.

"We want to see our people live with dignity. We want to see people own a house without worrying about eviction. We want people to own land unafraid that someone will violate their ownership. We want to see them have forests without worrying that someone will destroy it for their own interest," he said. "We want to see people live equally as humans, as Khmer citizens."

Protection of Cambodian citizens and their rights, he said, ought to be more of a priority for the government than protecting loggers, tycoons and the wealthy elite.

"I want to send a message to the court that even though today you may prosecute me, in the future, I believe that history will prosecute you all," he said.

Chandaravuth had already spent five months in prison after being arrested on June 16, 2021, while taking water samples at Tonle Sap River in Phnom Penh. Following his release he returned to environmental activism. He appeared in Mother Nature Cambodia's latest video, published on May 16, 2024, highlighting the toxic pollution of a river in the northwestern province of Battambang that was linked to a nearby factory. At the time of writing, the video has been viewed more than 55,000 times.

Ouch Pichsamnang, a veteran activist not associated with Mother Nature Cambodia, appeared in support of the young environmentalists, saying the trial reflects the suffering in Cambodia.

"Journalists and international journalists, please know that the government does not follow the Constitution," he said. "Anyone who follows the Paris Peace Agreements or the law has been arrested."

Mother Nature Cambodia was the recipient of the Right Livelihood Award in 2023 for its continued activism in the face of adversity. A short documentary was recently released on the impact that their time in prison — as well as their likely return to it — was having on the lives of the activists.

Banner image: Thun Ratha turns and waves to his wife and child as he enters the court to face conspiracy charges for his environmental activism. Image by Gerald Flynn / Mongabay.



តមកពីទំព័រទី ១០

## តើប៉ាឡេស្ទីនអាចក្លាយជាសមាជិក...

សិទ្ធិបោះឆ្នោតវេតូឬជំទាស់របស់ក្រុមប្រឹក្សាសន្តិសុខ គឺជាការកំណត់ទៅលើឋានៈរបស់ប្រទេសសាមីខ្លួន។

សមាជិកពេញសិទ្ធិរបស់អង្គការសហប្រជាជាតិ ចាំបាច់ត្រូវតែមានការអនុម័តយល់ព្រមជាមុនពីសមាជិកនៃក្រុមប្រឹក្សាសន្តិសុខដែលមានសមាជិក ១៥ប្រទេស ហើយក្រោយមកទើបគេប្រគល់កិច្ចការនេះទៅឱ្យមហាសន្និបាតជាអ្នកបោះឆ្នោតសម្រេចម្តងទៀត។

ជាច្រើនដងមកហើយ ការប្រឹងប្រែងរបស់ប៉ាឡេស្ទីន តែងជួបរឿងបរាជ័យ ដោយសារតែការបោះឆ្នោតជំទាស់របស់សហរដ្ឋអាមេរិក ដែលជាសម្ព័ន្ធមិត្តរបស់អ៊ីស្រាអែល។

ជាក់ស្តែងកាលពីខែមេសា កន្លងទៅ តំណាងរដ្ឋការសហរដ្ឋអាមេរិកនៅអង្គការសហប្រជាជាតិ បានបោះឆ្នោតជំទាស់នឹងការផ្តល់ជាសមាជិកភាពពេញសិទ្ធិសម្រាប់ប៉ាឡេស្ទីន ដោយអះអាងថា ការធ្វើបែបនេះមិនមែនជាមធ្យោបាយមានប្រសិទ្ធភាពក្នុងការជំរុញដំណោះស្រាយរដ្ឋពីរនោះទេ។

បើតាមគោលការណ៍ សំណើសុំទទួលបានឋានៈជាសមាជិកអង្គការសហប្រជាជាតិពេញសិទ្ធិ ជាដំបូងបំផុត គឺចាំបាច់ត្រូវតែទទួលបានការអនុម័តយល់ព្រមពីក្រុមប្រឹក្សាសន្តិសុខ ដែលជាស្ថាប័នធ្វើសេចក្តីសម្រេចចិត្តកំពូលរបស់ស្ថាប័នពិភពលោកមួយនេះ។ សំណុំរឿងប៉ាឡេស្ទីន នេះ មហាសន្និបាតតែឯងមិនអាចផ្តល់សមាជិកភាពពេញសិទ្ធិបានទេ។

សព្វថ្ងៃនេះ ប៉ាឡេស្ទីន មានឈ្មោះត្រឹមជារដ្ឋសង្កេតការណ៍ មិនមែនសមាជិកដែលជាឋានៈមួយត្រូវបានផ្តល់ឱ្យដោយមហាសន្និបាតអង្គការសហប្រជាជាតិ កាលពីឆ្នាំ២០១២ នោះទេ។

ក្រុមប្រឹក្សាសន្តិសុខ គឺជាស្ថាប័នកំពូលមួយក្នុងចំណោមទាំង ៥ នៃអង្គការសហប្រជាជាតិ។ ស្ថាប័ននេះមានសមាជិក ១៥ប្រទេស ក្នុងនោះសមាជិកអចិន្ត្រៃយ៍មាន ៥ប្រទេស ដែលទំនួលខុសត្រូវលើការធានានូវសន្តិភាព និងសន្តិសុខអន្តរជាតិ និងផ្តល់អនុសាសន៍ឱ្យទទួលសមាជិកថ្មីទៅកាន់មហាសន្និបាត។ អំណាចរបស់ស្ថាប័ននេះរួមមាន ការបង្កើតប្រតិបត្តិការរក្សាសន្តិភាព ការដាក់ទណ្ឌកម្មជាអន្តរជាតិ និងការអនុញ្ញាតសកម្មភាពយោធាក្រោមក្របខ័ណ្ឌរបស់អង្គការសហប្រជាជាតិ ដែលហៅថា «ទ័ពរក្សាសន្តិភាព»។

ក្រុមប្រឹក្សាសន្តិសុខ គឺជាស្ថាប័នតែមួយគត់របស់អង្គការសហប្រជាជាតិ ដែលមានសិទ្ធិអំណាចក្នុងការចេញសេចក្តីសម្រេចដាក់ការបង្ខំទៅណាប្រទេសណាមួយដែលត្រូវតែអនុវត្តតាម។ តែបើការសម្រេចវិធានការណាមួយធ្វើទៅបាន លុះត្រាមានសំឡេងឯកច្ឆន្ទដោយគ្មានសំឡេងជំទាស់ពីសមាជិកអចិន្ត្រៃយ៍ណាមួយ។ សមាជិកអចិន្ត្រៃយ៍មាន ៥ប្រទេស គឺសហរដ្ឋអាមេរិក អង់គ្លេស បារាំង រុស្ស៊ី និងចិន។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ភាសាអង់គ្លេសថា «Resolution»។

ប៉ាឡេស្ទីន ឆក់ឱកាសម្តងទៀតសុំឋានៈជាសមាជិកពេញសិទ្ធិរបស់អង្គការសហប្រជាជាតិ ចំពេលសង្គ្រាមផ្ទុះពេញទំហឹងនៅដែនដីហ្គាហ្សា។

កិច្ចប្រឹងប្រែងស្នើសុំសមាជិកភាពអង្គការសហប្រជាជាតិពេញសិទ្ធិរបស់ប៉ាឡេស្ទីន កើតមានឡើងចំពេលដែលសង្គ្រាមរវាងអ៊ីស្រាអែល និងក្រុមហាម៉ាស-ប៉ាឡេស្ទីន នៅតំបន់ហ្គាហ្សា បានអូសបន្លាយជាង ៧ខែមកហើយ។ នៅក្នុងការបោះឆ្នោតនៃមហាសន្និបាតអង្គការសហប្រជាជាតិ ទាំងអ៊ីស្រាអែល និង សហរដ្ឋអាមេរិក បានបោះឆ្នោតជំទាស់។ ខណៈនេះ អ៊ីស្រាអែលនៅតែត្រូវបានសហរដ្ឋអាមេរិកចាត់ទុកជាសម្ព័ន្ធមិត្តស្លាប់រស់នឹងគ្នា ដើម្បីភូមិសាស្ត្រនយោបាយ និងយោធានៅមជ្ឈិមបូព៌ា។

ចំពោះសង្គ្រាមនៅតំបន់ហ្គាហ្សា ដែនដីប៉ាឡេស្ទីន គឺជាសង្គ្រាមអ៊ីស្រាអែលវាយសងសឹក ព្រោះតែក្រុមហាម៉ាសជ្រកកោនលើដែនដីហ្គាហ្សា បានលួចវាយប្រហារបាញ់គ្រាប់រ៉ុក្កែតប្រមាណជា ៥០០គ្រាប់ចូលដែនដីអ៊ីស្រាអែល កាលពីថ្ងៃទី៧ ខែតុលា ឆ្នាំ២០២៣។ ទង្វើរបស់ពួកហាម៉ាស ដូចនេះ បាននាំឱ្យសហរដ្ឋអាមេរិកចាត់ទុកជាអំពើភេរវកម្ម ដែលសម្លាប់ប្រជាជនអ៊ីស្រាអែល ជាង ១២០០ នាក់។

យ៉ាងណា សង្គ្រាមនៅហ្គាហ្សា-ប៉ាឡេស្ទីន ដែលអ៊ីស្រាអែល លើកទ័ពចូលលុកលុយវាយបានស្ទើរទាំងស្រុង ហើយ តែសង្គ្រាមនេះ អ៊ីស្រាអែលមានផែនការកាត់ឫសគល់ និងវាយបំបែកសម្បុកអង្គការចាត់តាំងរបស់ពួកហាម៉ាស ដែលអ៊ីស្រាអែលហៅថាជាកម្លាំងភេរវកម្មនិយមជ្រកក្រោមផ្ទាំងផ្លាកការពារដែនដីប៉ាឡេស្ទីន។

នៅពេលដែលអ៊ីស្រាអែល វាយបែកសម្បុកពួកហាម៉ាសស្ទើរទាំងស្រុងមកដល់ពេលនេះ ប្រធានាធិបតីប៉ាឡេស្ទីន ម៉ាមូតអាម៉ាស បានថ្លែងដោះដៃថា ក្រុមហាម៉ាស មិនស្ថិតក្នុងកម្លាំងអាវុធជាតិរបស់ប៉ាឡេស្ទីន នោះទេ។ តាមមើលទៅប្រធានាធិបតីប៉ាឡេស្ទីន ចង់ប្រាប់ពិភពលោកថា ក្រុមនេះមានវត្តមាននៅលើទឹកដីហ្គាហ្សាជាទង្វើខុសច្បាប់។ តែគេថា ក្រុមនេះទទួលបានការផ្គត់ផ្គង់អាវុធ និងទ្រទ្រង់ថវិកាពង្រឹងកម្លាំងដោយប្រទេសអ៊ីរ៉ង់។

ដូចនេះហើយ មើលទៅបានជាសហរដ្ឋអាមេរិកសម្រេចបោះឆ្នោតជំទាស់ប្រឆាំងនឹងសំឡេងភាគច្រើនរបស់ប្រទេសដែលគាំទ្រសំណើសុំឋានៈជាសមាជិករបស់អាជ្ញាធរដែនដីប៉ាឡេស្ទីននៅក្នុងការបោះឆ្នោតរបស់មហាសន្និបាតអង្គការសហប្រជាជាតិ កាលពីថ្ងៃទី១០ ឧសភា កន្លងមកនេះ។

យ៉ាងណាជោគវាសនារបស់ប៉ាឡេស្ទីន ដែលចង់ក្លាយជាសមាជិកអង្គការសហប្រជាជាតិ គឺត្រូវឆ្លងកាត់ឆន្ទៈរបស់សហរដ្ឋអាមេរិក នៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ

តទៅទំព័រទី២០

## Analysis: Can Palestine become a full member of the United Nations?

From Page 15

Assembly on May 10, 25 countries abstained.

According to Chapter 5 of the UN Charter on the Right to Vote or Opposition, all 15 members of the UN Security Council, including the five permanent members, are required.

Opposition elections were held in the United States, Britain, France, Russia and China. If any of these five countries vote against, it is a block to the resolution or decision of this most powerful Security Council body. Russia, for example, voted against demanding the withdrawal of Russian troops from Ukraine is effective, even if China abstains.

Russia's opposition vote or veto has led to a complete blockade of a UN resolution calling for an end to the war in Ukraine. As for China's abstention, it is said that Beijing has shown its willingness not to weigh Russia on Ukraine's aggression.

After all, it is said that the fate of Palestine is in the hands of the United States. In this case, if the United States objects, Palestine will not be able to become a full member of the United Nations. But if the United States abstains, it will pave the way for another election at the UN General Assembly.

According to the election principle, a majority vote is required for a majority vote, with nine or more votes required to have sufficient weight of support. But if there is any veto from the permanent member, it blocks the decision completely.

For example, the forthcoming Security Council resolution, if abstention, including the United States, will not be able to block the case of the Palestinian Authority. In other words, unless a permanent member votes against, not even the United States, the Palestinian proposal can be blocked.

But in all cases, both at the UN General Assembly and at the Security Council, it is rare that an abstention vote outweighs the vote. Therefore, the Palestinian Authority's application for full membership in the United Nations is in the hands of the United States or any permanent country if they veto or oppose.


ក្រុមការងារសហគមន៍
កិច្ចប្រជុំក្រុមប្រឹក្សាភិបាល
ថ្ងៃពុធ ទី ២៦/៦/២០២៤ ម៉ោង ៦:៣០ ល្ងាច
បន្ទប់ក្រុមប្រឹក្សាជាន់ទី ២
155 ផ្លូវ Merrimack ឡូវែល
សូមស្វាគមន៍ជាសាធារណៈ

COMM UNITY TEAM WORK
Building Communities Changing Lives

Community Teamwork
Board of Directors Meeting
Wednesday, 6/26/24, 6:30pm
2nd Floor Board Room
155 Merrimack St., Lowell
PUBLIC WELCOME
To participate, RSVP:
sruas@commteam.org

តមកពីទំព័រទី ១៨

## ចាប់ផ្ដើមកាត់ក្ដីសកម្មជនមាតាធម្មជាតិ

ឃើញប្រជាជនមានផ្ទះដោយមិនខ្វល់ពីការបណ្ដេញចេញ។ យើងចង់ឲ្យប្រជាពលរដ្ឋមានដីដោយមិនខ្លាចមាននរណាម្នាក់រំលោភលើកម្មសិទ្ធិរបស់ខ្លួន។ យើងចង់ឃើញពួកគេមានព្រៃឈើដោយមិនបារម្ភថាមាននរណាម្នាក់នឹងបំផ្លាញវាដើម្បីផលប្រយោជន៍របស់ពួកគេ៉។ យើងចង់ឃើញមនុស្សរស់នៅស្មើភាពគ្នា ជាពលរដ្ឋខ្មែរ៉។

លី ច័ន្ទតារាវុធ ក្រឡេកមើលទៅក្រោយ ពេលគាត់ និងសកម្មជនអង្គការ ខែឧសភា ឆ្នាំ ២០២៤ ដោយបង្ហាញពីការបំពុលទឹកទន្លេមួយនៅភាគពាយព្យនៃខេត្តបាត់ដំបង ដែលពាក់ព័ន្ធនឹងរោងចក្រក្បែរនោះ។ វីដេអូនេះត្រូវបានគេមើលជាង ៥៥ ០០០ ដង។

អ៊ុច ពេជ្រសំណាង សកម្មជនជើងចាស់ដែលមិនពាក់ព័ន្ធជាមួយអង្គការមាតាធម្មជាតិកម្ពុជា បានចេញមុខគាំទ្រក្រុមអ្នកបរិស្ថានវ័យក្មេងដោយនិយាយថា ការកាត់ក្ដីនេះឆ្លុះបញ្ចាំងពីទុក្ខលំបាកនៅកម្ពុជា។



Ly Chandaravuth looks back as he and fellow Mother Nature Cambodia activists enter the court on May 29, 2024 to stand trial on conspiracy charges. Image by Gerald Flynn / Mongabay.

មាតាធម្មជាតិកម្ពុជា ចូលតុលាការកាត់ទោសពីបទសមគំនិត នៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៤។ រូបភាពដោយ Gerald Flynn / Mongabay ។

លោកថា ការការពារពលរដ្ឋខ្មែរ និងសិទ្ធិរបស់ពួកគេ គួរតែជាអាទិភាពសម្រាប់រដ្ឋាភិបាល ជាងការការពារអ្នកកាប់ឈើ ឧកញ៉ា និងក្រុមអ្នកមានលុយ។

លោកបានថ្លែងថា៖ "ខ្ញុំចង់ផ្ញើសារទៅតុលាការថា ទោះថ្ងៃនេះអ្នកអាចកាត់ទោសខ្ញុំក៏ដោយ ថ្ងៃអនាគត ខ្ញុំជឿថាប្រវត្តិសាស្ត្រនឹងកាត់ទោសអ្នកទាំងអស់គ្នាវិញ៉។

លោក ចាន់ តារាវុធ បានជាប់ពន្ធនាគាររយៈពេលប្រាំខែរួចហើយបន្ទាប់ពីត្រូវបានចាប់ខ្លួនកាលពីថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ ២០២១ ខណៈកំពុងយកសំណាកទឹកនៅទន្លេសាបក្នុងរាជធានីភ្នំពេញ។ បន្ទាប់ពីការដោះលែង លោកបានវិលទៅធ្វើជាសកម្មជនបរិស្ថានវិញ។ គាត់បានបង្ហាញខ្លួននៅក្នុងវីដេអូចុងក្រោយបង្អស់របស់អង្គការមាតាធម្មជាតិកម្ពុជាដែលបានចេញផ្សាយនៅថ្ងៃទី ១៦

លោកបានមានប្រសាសន៍ថា "អ្នកសារព័ត៌មាន និងអ្នកសារព័ត៌មានអន្តរជាតិ ត្រូវដឹងថា រដ្ឋាភិបាលមិនអនុវត្តតាមរដ្ឋធម្មនុញ្ញទេ៉។ "អ្នកណាក៏ដោយដែលធ្វើតាមកិច្ចព្រមព្រៀងសន្តិភាព ទីក្រុងប៉ារីស ឬច្បាប់ត្រូវបានចាប់ខ្លួន៉។

អង្គការមាតាធម្មជាតិកម្ពុជា ទទួលបានពានរង្វាន់ The Right Livelihood Award ក្នុងឆ្នាំ ២០២៣ សម្រាប់ការបន្តសកម្មជនភាពរបស់ខ្លួនក្នុងការប្រឈមមុខនឹងរឿងរ៉ាវលំបាកលំបិន។ ភាពយន្តឯកសារខ្លីមួយត្រូវបានចេញផ្សាយនាពេលថ្មីៗនេះ ស្ដីពីផលប៉ះពាល់ក្នុងអំឡុងពេលពួកគេនៅក្នុងពន្ធនាគារ - ក៏ដូចជាការវិលត្រឡប់របស់ពួកគេទៅធ្វើជាសកម្មជនបរិដ្ឋាន - កំពុងមានលើជីវិតរបស់សកម្មជន។

រូបភាពបដា៖ ថន រដ្ឋា ងាកមកគ្រីដៃដាក់ប្រពន្ធកូនពេលចូលតុលាការប្រឈមនឹងការចោទប្រកាន់ពីបទសមគំនិតធ្វើសកម្មភាពបរិស្ថាន។ រូបភាពដោយ Gerald Flynn / Mongabay ៕

តមកពីទំព័រទី ១៩

## តើប៉ាឡេស្ទីនអាចក្លាយជាសមាជិក...

ជាថ្មីម្ដងទៀត។

**តើប៉ាឡេស្ទីន អាចក្លាយជាសមាជិកអង្គការសហប្រជាជាតិបានដែរឬទេ?**

នៅប៉ុន្មានថ្ងៃទៀតនេះ គេរំពឹងថាក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិនឹងបើកកិច្ចប្រជុំម្ដងទៀតតាមសំណើរបស់ប្រទេសណាមួយដែលជាសមាជិកនៃក្រុមប្រឹក្សាសន្តិសុខ ដែលធ្វើតាមការសុំអនុសាសន៍ចេញពីលទ្ធផលនៃការបោះឆ្នោតលើសំណុំរឿងរបស់អាជ្ញាធរប៉ាឡេស្ទីន ដែលទទួលបានការគាំទ្រលើសលប់ពីប្រទេសជាសមាជិកអង្គការសហប្រជាជាតិរហូតដល់ ១៤៣ប្រទេសក្នុងចំណោមប្រទេសសរុបចំនួន ១៩៣ប្រទេស កាលពីថ្ងៃសុក្រសប្ដាហ៍មកនេះ។ តែយ៉ាងណាជោគវាសនារបស់ប៉ាឡេស្ទីន គឺពិតណាស់ត្រូវពឹងផ្អែកសហរដ្ឋអាមេរិកទាំងស្រុង។

ក្នុងគោលការណ៍នៃការបោះឆ្នោតរបស់សមាជិកនៃក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ មាន ៣ប្រភេទ គឺដូចនឹងការបោះឆ្នោតរបស់មហាសន្និបាតអង្គការសហប្រជាជាតិដែរ គឺមានទម្រង់បោះឆ្នោតគាំទ្រ ការបោះឆ្នោតអនុប្បវាទ និងការបោះឆ្នោតជំទាស់។

ក្នុងទម្រង់បោះឆ្នោត ៣ប្រភេទនេះ សន្លឹកឆ្នោតដែលមានទម្ងន់មានសន្លឹកឆ្នោតគាំទ្រ និងសន្លឹកឆ្នោតជំទាស់ ឬប្រឆាំង។ ចំណែកសន្លឹកឆ្នោតអនុប្បវាទ មិនមានទម្ងន់នោះទេ។ គេចាត់ទុកសន្លឹកឆ្នោតអនុប្បវាទ គ្រាន់តែជាការបញ្ចេញឆន្ទៈដើម្បីបញ្ជាក់ពីវត្តមានរបស់ពួកគេនៅក្នុងកិច្ចប្រជុំ ហើយម្យ៉ាងទៀតមិនចង់ឱ្យខ្លួនគេជាប់ពាក់ព័ន្ធអ្វីឡើយ។ មានន័យថាពួកគេចង់ឈរនៅចំណុចកណ្ដាល។

នៅក្នុងការបោះឆ្នោតនៅក្នុងមហាសន្និបាតអង្គការសហប្រជាជាតិ កាលពីថ្ងៃទី១០ ខែឧសភា មានប្រទេសចំនួន២៥ បោះឆ្នោតអនុប្បវាទ។

យោងតាមជំពូក៥ នៃធម្មនុញ្ញរបស់អង្គការសហប្រជាជាតិស្ដីពីបុព្វសិទ្ធិនៃការបោះឆ្នោតវេតូ ឬជំទាស់ គឺគេតម្រូវបានគ្រប់សមាជិកទាំង ១៥ប្រទេស ដែលជាសមាជិកក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ដោយរាប់ទាំងសមាជិកអចិន្ត្រៃយ៍ ៥ប្រទេសផងដែរ។

តែការបោះឆ្នោតជំទាស់ គេផ្ដល់សិទ្ធិខ្លាំងបំផុតសម្រាប់តែប្រទេសសមាជិកអចិន្ត្រៃយ៍ ៥ប្រទេសប៉ុណ្ណោះ ដែលមានសហរដ្ឋអាមេរិក អង់គ្លេស បារាំង រុស្ស៊ី និងចិន។ បើប្រទេសណាមួយក្នុងចំណោម ៥ប្រទេសនេះបោះឆ្នោតជំទាស់ គឺជាការរាំងខ្ទប់ Resolution ឬសេចក្ដីសម្រេចរបស់ស្ថាប័នក្រុមប្រឹក្សាសន្តិសុខដ៏មានឥទ្ធិពលបំផុតមួយនេះ។ ឧទាហរណ៍ រុស្ស៊ីបោះឆ្នោតជំទាស់ចំពោះការទាមទារឱ្យដកទ័ពរុស្ស៊ីចេញពីទឹកដីអ៊ុយក្រែន គឺមានប្រសិទ្ធភាព បើទោះជាប្រទេសចិន បោះឆ្នោតអនុប្បវាទក៏ដោយ។

ការបោះឆ្នោតជំទាស់ ឬវេតូរបស់រុស្ស៊ីបាននាំទៅរកការរាំងខ្ទប់សេចក្ដីសម្រេចទាំងស្រុងរបស់អង្គការសហប្រជាជាតិជួយបញ្ចប់សង្គ្រាមនៅអ៊ុយក្រែន។ ចំណែកសន្លឹកឆ្នោតអនុប្បវាទរបស់ចិន គេថាក្រុងប៉េកាំង បង្ហាញឆន្ទៈរបស់ខ្លួនមិនដាក់ទម្ងន់ទៅលើប្រទេសរុស្ស៊ី ដែលលើកទ័ពឈ្លានពានរបស់អ៊ុយក្រែន នោះទេ។

យ៉ាងណាមិញ គេថាជោគវាសនារបស់ប៉ាឡេស្ទីន គឺស្ថិតក្នុងដៃរបស់សហរដ្ឋអាមេរិក។ ករណីនេះ បើសហរដ្ឋអាមេរិកជំទាស់ គឺប៉ាឡេស្ទីន នៅតែមិនអាចក្លាយជាសមាជិកពេញសិទ្ធិរបស់អង្គការសហប្រជាជាតិបានឡើយ។ តែបើសហរដ្ឋអាមេរិកបោះឆ្នោតអនុប្បវាទ គឺជាការបើកផ្លូវឱ្យមានការបោះឆ្នោតម្ដងទៀតនៅឯមហាសន្និបាតអង្គការសហប្រជាជាតិ។

តាមគោលការណ៍នៃការបោះឆ្នោត គេតម្រូវឱ្យមានសន្លឹកឆ្នោតគាំទ្រភាគច្រើនជាងសំឡេងអនុប្បវាទ គឺគេតម្រូវថាមានសំឡេង ៩រូបឡើងទៅ ទើបមានទម្ងន់គ្រប់គ្រាន់នៃការគាំទ្រ តែបើមានសំឡេងវេតូ ឬជំទាស់ណាមួយពីសមាជិកអចិន្ត្រៃយ៍ គឺជាការបិទខ្ទប់សេចក្ដីសម្រេចទាំងស្រុង។

ឧទាហរណ៍ការសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខម្ដងទៀតខាងមុខនេះ បើមានសំឡេងអនុប្បវាទដោយរាប់ទាំងសហរដ្ឋអាមេរិកផងដែរ នឹងមិនអាចរាំងខ្ទប់សំណុំរឿងរបស់អាជ្ញាធរដែនដីប៉ាឡេស្ទីនបានឡើយ។ និយាយទៅ លុះត្រាតែសមាជិកអចិន្ត្រៃយ៍ណាមួយបោះឆ្នោតជំទាស់ ទោះជាមិនមែនសហរដ្ឋអាមេរិកក៏ដោយ ក៏អាចបិទខ្ទប់សំណើរបស់ប៉ាឡេស្ទីន បានដែរ។

តែរាល់ករណីទាំងអស់ ទាំងនៅឯមហាសន្និបាតអង្គការសហប្រជាជាតិ និងនៅឯក្រុមប្រឹក្សាសន្តិសុខ កម្រនឹងកើតមានសំឡេងឆ្នោតអនុប្បវាទមានច្រើនជាងសំឡេងគាំទ្រ។ ដូច្នេះ សំណើសុំឋានៈជាសមាជិកពេញសិទ្ធិនៃអង្គការសហប្រជាជាតិរបស់អាជ្ញាធរប៉ាឡេស្ទីន គឺស្ថិតក្នុងដៃសហរដ្ឋអាមេរិក ឬប្រទេសអចិន្ត្រៃយ៍ណាមួយ ប្រសិនបើពួកគេបោះឆ្នោតវេតូ ឬជំទាស់៕



## កំពាព្យខ្មែរ



ជម្រាបសួរបងប្អូនកូនចៅទាំងអស់គ្នា ញាតិសន្តាន និងប្រជាជនខ្មែរទាំងអស់គ្រប់គ្នា!

ខ្ញុំឈ្មោះអ្នកគ្រូ ពឹង សយ សូមជូនកំណាព្យមួយ ហើយកំណាព្យនេះខ្ញុំបានតែងយូរហើយ តែជាកំណាព្យដែលខ្ញុំចង់រំលឹកនូវអ្វីដែលខ្ញុំគិតកន្លងមក ហើយអ្វីដែលខ្ញុំគិតនេះគឺនឹងបន្តទៅមុខទៀតជារៀងរហូត។ ដូច្នេះ សូមជូនជាសណ្ដាប់ដូចតទៅ៖

ធម្មជាតិមនុស្សសត្វ
ទៅកាន់ទីទៃ

កាលបើព្រាត់ខ្ចាត់
ឆ្ងាយញាតិសណ្ដាន
ចង់វិលវិលវៃ។

ចេញពីភូមិឋាន
អារម្មណ៍ជាប់ប្រាណ

ស្រុកកំណើតខ្ញុំ
ជាតំបន់ល្អ

ស្ថិតនៅក្នុងម្ដុំ
មានសព្វអ្វីៗ
ក្នុងព្រៃប្រឹក្សា។

សុវណ្ណដែនដី
ក្នុងទឹកក្នុងដី

ដីវាលព្រៃរបោះ
ខ្ពង់រាបប៉ប្រះ

ទំនាបបាតខ្វះ
ជើងព្រៃបុព្វតា
រក្សាបរិដ្ឋាន។

ដីស្រែចំការ
ស្រទាប់រុក្ខា

ជ្រលងដងអូរ
ហូរបំពេញបឹង

បើកផ្លូវទឹកហូរ
ចែកសព្វទីឋាន
ចូលមហាសាគរ។

ទៅតាមលំអាន
ទន្លេស្ទឹងប្រាន

ក្នុងទឹកមានត្រី
ការពារអាកាស

រ៉ែមានក្នុងដី
ដែលបាតុភូតបង្ករ
រស់ស្រួលឥតភ័យ។

ព្រៃស្រោងដៃឈរ
អ្នកស្រុកសាទរ

មេឃមីស្រទំ
ឆ្ងល់ថាហេតុម្ដេច

ធ្វើអោយចិត្តខ្ញុំ
ខ្មែររស់ក្រក្រី
បរិបូណ៌ឥតខ្វះ។

នឹកគិតស្រមៃ
នៅលើទឹកដី

មេឃខ្មៅងងិត
មានមនុស្សចោរពោ

ខ្ញុំជញ្ជឹងគិត
ទន្ទ្រានបោកប្រាស់

ឃើញហេតុផលច្បាស់
បំផ្លាញទឹកដី។

កាប់ឈើវាលព្រៃ
ជួលដីសម្បទាន

ជីករ៉ែក្នុងដី
ខ្មែរអស់របរ
ធ្វើចំណាកស្រុក។

វាយភ្នំយកថ្ម
ធ្លាក់ខ្លួនក្រីក្រ

ខ្មែរអើយៗខ្មែរ
រំពឹងជំនួយ

កុំរង់ចាំតែ
នាំព្រួយដាក់មុខ
ត្រូវតែមាក់ងាយ។

គេផ្ដល់ក្ដីសុខ
បាត់ភាពម្ចាស់ស្រុក

មេឃអើយៗមេឃ
ជួយមើលសុខទុក្ខ

កុំនៅឆ្ងាយពេក
មនុស្សសត្វទាំងឡាយ
ដោយមនុស្សលោភលន់។

បន្ទាបមកអោយ
ជួបភ័យអន្តរាយ

មេឃភ្លឺល្អះហើយ
ដាស់គ្នាអោយក្រោក

ខ្មែរភ្ញាក់ខ្លួនហើយ
ជួយរែកជួយពន់
អភិវឌ្ឍស្រុកយើង។

លែងស្ពឹកស្រពន់
ចងជាសម្ព័ន្ធ

យើងខ្មែរគ្រប់គ្នា
ជាទីប្រាថ្នា

ត្រូវចង់ចាំថា
នែមនុស្សឈាមឈ្លើង
សកម្មភាពការពារ។

សុវណ្ណភូមិដីយើង
ខ្មែរត្រូវតម្លើង

ភាពខ្មៅងងិត
ខ្យល់បក់រំភើយ
ស្នេហាទឹកដី។

នឹងលែងសន្ថិត
ត្រជាក់កាយា

ក្នុងចិត្តគ្រប់គ្នា
ដុះខាតមនសិកា

យុវជនខ្មែរអើយ
គឺអ្នកនេះហើយ

អាសន្នទៀតហើយត
ជាទំពាំងឬស្សី
គឺការពារជាតិ។

គ្រោះបាត់អធិបតេយ្យ
សកម្មភាពអ្នកថ្លៃ

យុវវ័យក្លៀវក្លា
ចំពោះឧបសគ្គ

ទឹកចិត្តមុតថ្លា
មិនដែលចាញ់ច្រាប
ធ្វើពលិកម្ម។

ប្រាជ្ញាវៃឆ្លាត
លះបង់ដាច់ខាត

អាទិភាពឧត្ដម
ទើបបូរណភាព

ទាល់តែខ្មែរខំ
ទឹកដីរឹងមាំ
ពូជសាងអង្គរ។

មើលថែប្រចាំ
ឈ្មោះខ្មែរសក្តិសម

### NOTICE OF PUBLIC MEETING

The next meeting of the Northern Middlesex Metropolitan Planning Organization (MPO) will be held on June 26, 2024 at 2:00 PM. NMMPO meetings are held virtually via Zoom and in person at 672 Suffolk Street, Suite 100, Lowell, MA. The full agenda and information about the meeting will be posted at www.nmcog.org/calendar. The NMMPO provides reasonable accommodations and/or language assistance free of charge upon request (including but not limited to interpreters in American Sign Language and languages other than English, open or closed captioning for videos, assistive listening devices and alternate material formats), as available. For assistance, please contact Lesley Shahbazian at (978) 454-8021 or at lshahbazian@nmcog.org. Requests should be made for services requiring accommodations.

### សេចក្ដីជូនដំណឹងស្ដីពីកិច្ចប្រជុំជាសាធារណៈ

កិច្ចប្រជុំបន្ទាប់នៃអង្គការផែនការមេត្រូប៉ូលីតខាងជើង (MPO) នឹងប្រព្រឹត្តទៅនៅថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ ២០២៤ វេលាម៉ោង២:០០រសៀល។ កិច្ចប្រជុំ NMMPO ត្រូវបានធ្វើឡើងតាមរយៈវេទិកា Zoom និងដោយផ្ទាល់នៅអាសយដ្ឋាន 672 Suffolk Street, Suite 100, Lowell, MA ។ របៀបវារៈពេញលេញ និងព័ត៌មានអំពីកិច្ចប្រជុំនេះ នឹងត្រូវបានបង្ហោះនៅលើគេហទំព័រ www.nmcog.org/calendar ។ NMMPO ផ្ដល់នូវការស្នាក់នៅសមរម្យ និង/ឬជំនួយភាសាដោយមិនគិតថ្លៃតាមការស្នើសុំ (រួមទាំងប៉ុន្តែមិនកំណត់ចំពោះអ្នកបកប្រែជាភាសាសញ្ញាអាមេរិក និងភាសាផ្សេងក្រៅពីភាសាអង់គ្លេស មានអក្សររត់លើអេក្រង់ទូរទស្សន៍ មានឧបករណ៍ជំនួយការ ស្ដាប់ និងទម្រង់សម្ភារៈជំនួស) ។ សម្រាប់ជំនួយ សូមទាក់ទង Lesley Shahbazian តាមលេខ (978) 454-8021 ឬតាម lshahbazian@nmcog.org។ សម្រាប់សេវាស្នាក់នៅ សូមដាក់ពាក្យស្នើសុំ។

តមកពីទំព័រទី ១១

# ខ្មែរក្រោមនៅតែមិនមានសិទ្ធិសេរីភាព

ប្រធានាធិបតីបារាំង លោក វ៉ាន់ស៊ីង អូរីយ៉ូ បើតាមគណៈបក្សនោះចាប់តាំងពីពេលនោះមកពីពលរដ្ឋខ្មែរក្រោម បានក្លាយជាជនជាតិដើមភាគតិចនៅលើទឹកដីកំណើតរបស់ខ្លួនឯង សូមសម្តែងការសោកស្តាយពន់ពេក ចំពោះការបាត់បង់ទឹកដីកម្ពុជាក្រោមដែលយើងខ្ញុំចងចាំមិនអាចបំភ្លេចបាន ដែលក្នុងនោះបងប្អូនខ្មែរកម្ពុជាក្រោមគឺជាជនរួមឈាមខ្មែរតែមួយ ដែលត្រូវយកចិត្តទុកដាក់និងការគាំទ្រតាមដែលអាចធ្វើទៅបាន ប្រភពដដែលបញ្ជាក់ថាការផ្ទេរទឹកដីកម្ពុជាក្រោមទៅឲ្យប្រទេសវៀតណាមត្រួតត្រានេះ ជាមេរៀនប្រវត្តិសាស្ត្រដែលថ្នាក់ដឹកនាំខ្មែរជំនាន់ក្រោយៗ និងពលរដ្ឋខ្មែរគ្រប់និន្នាការត្រូវចងចាំ និងត្រូវរួបរួមគ្នាសាមគ្គីដើម្បីការពារទឹកដីដែលមានបច្ចុប្បន្នឱ្យបានគង់វង្សសម្រាប់កូនចៅជំនាន់ក្រោយ ជុំវិញបញ្ហានេះគណបក្សប្រជាធិបតេយ្យមូលដ្ឋាន អំពាវនាវទៅរដ្ឋាភិបាលកម្ពុជាធ្វើកិច្ចសហប្រតិបត្តិការជាមួយភាគីវៀតណាម ដើម្បីធានាថាជនជាតិដើមខ្មែរមានសិទ្ធិសេរីភាព គ្រប់គ្រាន់មានការគោរព សិទ្ធិមនុស្សជាមូលដ្ឋានជាពិសេសសិទ្ធិខាងវប្បធម៌ ជំនឿសាសនា និងសិទ្ធិពលរដ្ឋ ផ្សេងៗទៀតក្នុងការតវ៉ាទាមទារសម្តែងមតិនិងជួបជុំដែលស្របតាមច្បាប់អន្តរជាតិជាពិសេសសូមរាជរដ្ឋាភិបាលកម្ពុជាជជែកជាមួយភាគីវៀតណាមដើម្បីរៀបចំឲ្យមានបេសកកម្មកុងស៊ុល នៅប្រចាំតំបន់និងមានបេសកកម្មពីរាជរដ្ឋាភិបាលកម្ពុជាឲ្យបានទៀងទាត់ទៅតំបន់ដែលមានជនជាតិខ្មែរកម្ពុជាក្រោមរស់នៅ បន្ថែមពីនេះប្រធានគណៈកម្មាធិការដោះស្រាយវិវាទ និងវិន័យគណបក្សមូលដ្ឋាន លោក ធុកបូណាបានថ្លែងថាការចេញសេចក្តីថ្លែងការណ៍នេះគឺដើម្បីបង្ហាញថាកម្ពុជាក្រោមគឺជនជាតិខ្មែរតែមួយ ដែលមេដឹកនាំគួរតែបំពេញកាតព្វកិច្ចនេះហើយយើងក៏សុំអរគុណបងប្អូនខ្មែរកម្ពុជាក្រោម " ទោះបីជាមានការធ្វើទុក្ខបុកម្នេញពីសំណាក់អាជ្ញាធរ របស់ប្រទេសវៀតណាមយ៉ាងណាក្តីក៏ពួកគាត់នៅតែខិតខំតស៊ូជម្នះដើម្បីរក្សាវប្បធម៌ អក្សរសាស្ត្រ ប្រពៃណី របស់ដូនតាខ្មែរ" ។

សហស្ថាបនិកនៃគណបក្សកែទម្រង់កម្ពុជា និង ជាអតីតតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិ លោក អ៊ូ ច័ន្ទរ័ត្ន គាំទ្រការជំរុញនេះលោកគូសបញ្ជាក់ថា ការប្រាប់វៀតណាមឲ្យគោរពសិទ្ធិខ្មែរក្រោម ជារឿងចាំបាច់ដោយថាភាគីវៀតណាមជាញឹកញាប់តែងតែស្នើកម្ពុជាឲ្យការពារជនជាតិខ្លួន ដែលបានមករស់នៅលើទឹកដី កម្ពុជារួមទាំងអ្នកខុសច្បាប់ "ភ្លេចគិតពីបញ្ហានេះជាយូរណាស់ហើយ ព្រោះទោះបីជាប្រជាពលរដ្ឋខ្មែរខ្លួនឯងមិនរំលឹក ហើយរដ្ឋាភិបាលវៀតណាមហាក់ដូចគេក្រើនរំលឹកព្រោះគេការពារប្រជាពលរដ្ឋគេ នៅលើទឹកដីរបស់កម្ពុជាបច្ចុប្បន្នចឹងហាស ទាំងស្របច្បាប់ និងមិនស្របច្បាប់ ហើយជារដ្ឋាភិបាលមួយដែលធ្លាប់ជាម្ចាស់ទឹកដីទាំងកម្ពុជាក្រោមផងនោះ ហើយមានប្រជាពលរដ្ឋរស់នៅរាប់លាននាក់ ហើយអត់ដែលមានសារដល់រដ្ឋាភិបាលវៀតណាមហ្នឹងដើម្បីឲ្យការពារប្រយោជន៍ណ ការពារសិទ្ធិសេរីភាពរបស់ខ្មែរក្រោមទេ ចឹងហាសដូច្នេះគួរតែយកតម្រាប់តាមគេផង រដ្ឋាភិបាលវៀតណាមនោះ"។

ដោយឡែកគេហទំព័ររបស់មេដឹកនាំខ្មែររួមទាំង លោក ហ៊ុន សែន មិនបានបង្ហាញប្រតិកម្មករណីវៀតណាមរំលោភសិទ្ធិខ្មែរក្រោមនេះដែរដោយឡែកតំណាងរាស្ត្រគណបក្សជាតិលោក អ៊ុំ សំអាន ធ្លាប់និយាយថាបញ្ហានេះមកពីមេដឹកនាំខ្មែរជាប់ជំពាក់គុណវៀតណាម "រដ្ឋាភិបាល លោកហ៊ុន សែន ក៏ដូចជារដ្ឋាភិបាលលោក ហ៊ុន ម៉ាណែត ហ្នឹងគឺមិនហ៊ានប្រឆាំងរដ្ឋាភិបាលវៀតណាមនោះទេទោះបីជាវៀតណាមនេះជីកប្រឡាយនៅតាមព្រំដែននោះក៏អត់ហ៊ានឃាត់វៀតណាមដៃ វៀតណាមធ្វើអីស្រេចតែចិត្តហាស ដូច្នេះនៅពេលដែលរដ្ឋាភិបាលខ្លាចវៀតណាមចឹង វាធ្វើឲ្យបូរណភាពទឹកដីរបស់យើងបាត់បង់បន្ថែមទៀត ហើយថ្ងៃក្រោយទៅវាមែនតែបាត់បង់ទឹកដីតាមព្រំដែនទេណា នូវពេលដែលយួនហូរចូលច្រើនឡើងៗវាធ្វើអោយបាត់បង់ទឹកដីដូចកម្ពុជាក្រោមក៏ដូចជាទឹកដីចម្ប៉ាចឹងដែរ"តែយ៉ាងណាវិធានការណ៍របស់អាជ្ញាធរវៀតណាមទៅលើខ្មែរក្រោមបើទោះបីជាមេដឹកនាំខ្មែររក្សាភាពស្ងៀមស្ងាត់តែគេសង្កេតឃើញសហគមន៍អន្តរជាតិបញ្ចេញប្រតិកម្មក្នុងនោះមានទាំងសហរដ្ឋអាមេរិកទាមទារឲ្យវៀតណាមគោរពសិទ្ធិ ខាងជំនឿខ្មែរក្រោម សហរដ្ឋអាមេរិកនិយាយក្នុងសេចក្តីថ្លែងការចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០២៤ ថាខ្លួនមានការខកចិត្តចំពោះចំណាត់ការវៀតណាមដែលបានចាប់ខ្លួនសកម្មជនសិទ្ធិមនុស្ស និងចាប់ផ្សឹកព្រះសង្ឃខ្មែរក្រោមដែលជាអ្នកតស៊ូមតិដើម្បីសិទ្ធិសេរីភាពជំនឿសាសាព្រមទាំងផ្តន្ទាទោសមនុស្សចំនួន ០៥នាក់ ចាប់តាំងពីខែមករា ឆ្នាំ២០២៤ ទឹកដីកម្ពុជាក្រោមត្រូវបានរដ្ឋាភិបាលអាណានិគមន៍បារាំងចុះហត្ថលេខាប្រគល់ទៅឲ្យរដ្ឋាភិបាលវៀតណាមត្រួតត្រាបន្ត ចាប់តាំងពីឆ្នាំ០៤ មិថុនា ឆ្នាំ១៩៤៩ ដែលខ្មែរក្រោមចាត់ទុកជាអំពើខុសច្បាប់ ដែលទឹកដីខ្មែរក្រោមមានចំនួន២១ខេត្តក្រុង គិតត្រឹមឆ្នាំ២០២៤ ទឹកដីកម្ពុជាក្រោមស្ថិតក្នុងការត្រួតត្រារបស់វៀតណាមអស់រយៈពេល៧៥ឆ្នាំ នៅកម្ពុជាក្រោមវត្តអារាមត្រូវចាត់ទុកថាជាឃ្លាំងវប្បធម៌ជាទីកន្លែងថែរក្សាការពារអត្តសញ្ញាណខ្មែរក្រោមទាំងមូល។

ដោយឡែក កាលពីថ្ងៃទី១ និងថ្ងៃទី២ ខែមិថុនា សាខាសហព័ន្ធខ្មែរកម្ពុជាក្រោមនៅប្រទេសអូស្ត្រាលី (Australia) និងពលរដ្ឋខ្មែរនៅប្រទេសកូរ៉េខាងត្បូង (South Korea) បារាំង (France) អ៊ីតាលី (Italy) កាណាដា (Canada) និងសហរដ្ឋអាមេរិក (United States) ក៏បានប្រារព្ធពិធីនេះដែរ។ នៅសហរដ្ឋអាមេរិក (United States) នឹងធ្វើពិធីបាត់បង់ទឹកដី នៅទីក្រុងសានហូសេ (San Jose) រដ្ឋកាលីហ្វ័រនីញ៉ា (California)។ ចំណែកអង្គការ សមាគមខ្មែរកម្ពុជាក្រោមនៅកម្ពុជា គ្រោងប្រារព្ធពិធីនេះ នៅវត្តសាមគ្គីរង្សី ហៅវត្តខ្មែរកម្ពុជាក្រោម ក្នុងរាជធានីភ្នំពេញ៕

# Khmer Krom People Do Not Have Freedom Under Vietnamese Rule

From Page 11

dian government has never sent a message to the Vietnamese government to protect the interests and never "defend the rights and freedoms of the Khmer Krom."

Meanwhile, the websites of Cambodian leaders, including Mr. Hun Sen, did not react to the case of Vietnam violating the rights of the Khmer Krom. Mr. Oum Sam An of CNRP said this is because Cambodian leaders owe gratitude to Vietnam. "Hun Sen's government, as well as Hun Manet's government, does not dare oppose the Vietnamese government even though Vietnam dug canals along the border, it did not dare to stop Vietnam. It further destroys our territorial integrity, and the next day it will not only lose territory along the border, as Vietnamese flows in more and more, it loses territory like Kampuchea Krom and Champa."

However, the Vietnamese authorities 'actions against the Khmer Krom, despite the Khmer leaders' silence, have been observed by the international community, including the United States, demanding that Vietnam respect the Khmer Krom faith as mentioned in a statement by the United States on April 1, 2024: "Disappointed by Vietnamese action in arresting human rights activists and defrocked Khmer Krom monks who were advocates for freedom of religion and convicted five people since January 2024. The territory of Kampuchea Krom was signed by the French colonial government to be handed over to the Vietnamese government from June 4, 1949, which the Khmer Krom considered illegal, the territory of the Khmer Krom in 21 provinces as of 2024. The territory of Kampuchea Krom has been under Vietnamese control for 75 years.

On June 1 and 2, the Khmer Kampuchea Krom Federation branches in Australia, South Korea, France, Italy, Canada and the United States also celebrated the event. In the United States a groundbreaking ceremony will be held in San Jose, California. The Khmer Kampuchea Krom Association in Cambodia held this ceremony at Wat Samaki Rainsy called Wat Khmer Kampuchea Krom in Phnom Penh.


ខ្មែរនៅកូរ៉េគាំទ្រសាមគ្គីគ្នារវាងខ្មែរកណ្តាល និងខ្មែរក្រោម



# លោក ពូទីន មកដល់ វៀតណាម ដើម្បី ចាប់ផ្តើមដំណើរទស្សនកិច្ចដ៏សំខាន់

តាមការចុះផ្សាយរបស់ VN Express, ប្រធានាធិបតីរុស្ស៊ីលោកវ្ល៉ាឌីមៀរ ពូទីន បានមកដល់ប្រទេសវៀតណាមហើយ ដើម្បីចាប់ផ្តើមដំណើរទស្សនកិច្ចផ្លូវរដ្ឋ តាមការអញ្ជើញរបស់លេខាបក្សវៀតណាម លោក Nguyen Phu Trong។

យន្តហោះពិសេស Il-96-300PU ដឹកលោក ពូទីន និងមន្ត្រីអ្នកមុខអ្នកការរុស្ស៊ីដទៃទៀតបានចុះចតនៅអាកាសយានដ្ឋាន Noi Bai នាទីក្រុងហាណូយ វេលាម៉ោង ១:៤៥រំលងអធ្រាត្រ ហើយបន្ទាប់ពីការទទួលស្វាគមន៍ពីសំណាក់ថ្នាក់ដឹកនាំវៀតណាម ក្បួនរថយន្តដឹកប្រធានាធិបតីរុស្ស៊ី ក៏ឆ្ពោះដំណើរទៅសណ្ឋាគារ Metropole នៅក្នុងសង្កាត់ Hoan Kiem។

តាមការគ្រោងទុក លោក ពូទីន នឹងត្រូវចូលរួមក្នុងពិធីស្វាគមន៍ជាផ្លូវការនៅវិមានប្រធានាធិបតីនាពេលថ្ងៃត្រង់ មុនចាប់ផ្តើមកិច្ចសន្ទនាជាមួយប្រធានាធិបតីវៀតណាមលោក To Lam។ ក្រោយមក



លោក ពូ ទីន ធ្វើដំណើរទស្សនៈកិច្ចដល់ប្រទេសវៀតណាមហើយ

លោក ពូទីន នឹងជួបជាមួយនាយករដ្ឋមន្ត្រី Pham Minh Chinh និងសន្ទនាជាមួយលោក Trong រួចបន្តជួបជាមួយប្រធានរដ្ឋសភា Tran Thanh Man នាពេលរសៀល។

នាល្ងាចថ្ងៃដដែល លោកពូទីន នឹងទៅគោរពវិញ្ញាណក្ខន្ធលោក ហូជីមិញ មុនពេលជួបជាមួយប្រធានរដ្ឋសភា Tran Thanh Man។ លោក ពូទីន និង លោកToLam ក៏នឹងជួបជាមួយថ្នាក់ដឹកនាំសមាគមមិត្តភាពវៀតណាម-រុស្ស៊ី និងអតីតនិស្សិតដែលបានសិក្សានៅប្រទេសរុស្ស៊ីផងដែរ។


មេដឹកនាំវៀតណាមទទួលស្វាគមន៍លោក ពូ ទីន នៅប្រលានយន្ត

សូមបញ្ជាក់ថា ដំណើរទស្សនកិច្ចនេះ ធ្វើឡើងបន្ទាប់ពីលោក ពូទីន ទើបបញ្ចប់ទស្សនកិច្ចរយៈពេលខ្លីនៅប្រទេសកូរ៉េខាងជើង ដោយជួបពិភាក្សាជាមួយមេដឹកនាំ គីម ជុង អ៊ុន និងចុះហត្ថលេខាលើកិច្ចព្រមព្រៀងសំខាន់ៗជាច្រើន។

លោក ពូទីន ធ្លាប់មកប្រទេសវៀតណាម៤ដងរួចមកហើយ ក្នុងនោះមាន៣ដងស្ថិតក្នុងក្របខ័ណ្ឌនៃដំណើរទស្សនកិច្ចផ្លូវការនិងរដ្ឋក្នុងឆ្នាំ២០០១, ២០០៦ ឆ្នាំ ២០១៣ ចំណែកមួយដងទៀតគឺក្នុងឆ្នាំ២០១៧ នៅពេលលោកមកទីក្រុង Da Nang ដើម្បីចូលរួមកិច្ចប្រជុំកំពូល APEC។

វៀតណាម បានបង្កើតទំនាក់ទំនងការទូតជាមួយរុស្ស៊ីដែលជាអតីតសហភាពសូវៀត ក្នុងឆ្នាំ១៩៥០។ ក្រោយមក ប្រទេសទាំងពីរ បានអភិវឌ្ឍទំនាក់ទំនងទៅជាភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយក្នុងឆ្នាំ២០១២ ហើយប្រទេសទាំងពីរ បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងសហប្រតិបត្តិការជាង ១០០ ក្នុងវិស័យសេដ្ឋកិច្ច ពាណិជ្ជកម្ម វិនិយោគ សន្តិសុខ និងការពារជាតិ៕

អត្ថបទ៖ សុខ សុវណ្ណ

Eastern PHYSICAL THERAPY

ឈឺចុកចាប់មែនទេ ? យើងអាចជួយបាន៖

- របួសដោយសារគ្រោះថ្នាក់ចរាចរណ៍
- រអិល និងដួល
- ជំងឺរលាកសន្លាក់រ៉ាំរ៉ៃ
- ស្តារនីតិសម្បទា
- ព្យាបាលដោយការម៉ាស្សា
- ព្យាបាលបន្ទាប់ពី ការវះកាត់ឆ្អឹង និងមិនវះកាត់
- សំណងនៃការស្តារនីតិសម្បទាកម្មករ (Worker's Comp Rehab)

Have Aches & Pain? We Can Help.

- Injuries from Auto Accident
- Slip & Fall
- Chronic Arthritis
- Physical rehabilitation
- Massage Treatment
- Post Orthopedic Surgical and Non-Surgical
- Worker's Comp Rehab

We provide preventative and rehabilitative health services by licensed health professionals. We use exercise or stretching techniques/equipments to help relief pain or recover from injuries or surgeries and improve overall physical ability.

Eastern Physicial Therapy
851 Middlesex Street, Suite 1 Lowell, MA 01851
Phone: 978-677-6333 Fax: 978-677-6982

KhmerPost USA, LLC
សារព័ត៌មានខ្មែរបុសសហរដ្ឋអាមេរិក



អគ្គនាយក សុបិន្ន អ៊ឹង
Soben Ung, Co-Founder|Publisher
Cell: 978-656-8141
Soben@khmerpostusa.com

Ponnaro Aiden Pin,
Assistant to the Publisher

The KhmerPost USA is a free Monthly Cambodian newspaper and serves the Greater Merrimack Valley, Boston, and Rhode Island. It prints mostly in Khmer and provides important news and information to the people who often are isolated from the larger community due to a language barrier. This includes not only national and international news but practical local information concerning health, education, politics, businesses and community involvement. It publishes Once a month from Lowell, Massachusetts.

Design Artist Heng Chhun Leng

Article Submission
Khmerpostusa@gmail.com

Mail subscription is available within the U.S. & Canada at $60.00 year.
Free online edition at www.khmerpostusa.com

**PRINT READERSHIP**

*50,000 Monthly / 600,000 Annually*
*Plus additional exposure in our online editions at khmerpostusa.com*

**ONLINE EDITIONS AVAILABLE AT KHMERPOSTUSA.COM**

# 2024 PRINTING SCHEDULES

## EFFECTIVE JANUARY 1, 2024

## ADVERTISING RATES AND SIZES

*All ads are printed in Full Color*

**Ad Size (WxH)**

**Full Inside** (10" wide x 13" tall) . . . . $ 552.00
**1/2** (10" wide x 6.5" tall) . . . . . . . . . . . 375.00
**1/4** (5" wide x 6.5" tall) . . . . . . . . . . . . 192.00
**1/8** (5" wide x 3.25" tall) . . . . . . . . . . . 108.00
**Business Card** (3.5" wide x 2" tall) . . . 60.00

**Full Back Page** (10" wide x 13" tall) . . . . . . . . . $ 1000.00
**Front Page 1/2** (10" wide x 6.5" tall) . . . . . . . . . . 1000.00
**Front Page 1/4** (5" wide x 6.5" tall) . . . . . . . . . . . . 620.00
**Front Page 1/8** (5" wide x 3.25" tall) . . . . . . . . . . . 350.00
**Front Page Business Card** (3.5" wide x 2" tall) . . . 200.00

Your ad is also published in our online editions of the newspaper at khmerpostusa.com




## 2024 PRINTING DATES

***Advertising deadlines are 5 business days prior to printing date.***

| | | |
|---|---|---|
| January | 15 | Monday |
| February | 9 | Friday |
| March | 3 | Sunday |
| April | 1 | Monday |
| May | 1 | Wednesday |
| June | 1 | Saturday |
| July | 1 | Monday |
| August | 1 | Thursday |
| September | 1 | Sunday |
| October | 1 | Tuesday |
| November | 1 | Friday |
| December | 1 | Sunday |

## MONTHLY DISTRIBUTION

*70+ Locations in Lowell, MA • 7,000 copies*
*25 Locations in Lynn & Revere, MA • 1,000 copies*
*25 Locations in Providence & Cranston, RI • 2,000 copies*
*Additional distribution online*

## CONTACT INFO

**Khmer Post USA • P.O. Box 8848 • Lowell, MA 01853**
**Tel: 978.677.7163 • Fax: 978.677.7092**
**Email: khmerpostusa@gmail.com**
**www.khmerpostusa.com**

*Khmer Post USA is a proud member of New England Press & Newspaper Association and Greater Merrimack Valley Convention and Visitors Bureau*

***Khmer Post USA Distribution Locations Include:***

*Households • Markets • Retail Businesses*
*Restaurants • Office Buildings • Government Offices*
*Chamber of Commerce • Buddhist Temple*
*Laundromats • And Much More*

Follow us @KhmerPostUSA

Subscribe @KhmerPostUSA

Follow us @KhmerPostUSA